# និន្នាការទូទៅនៃវិនិយោគខ្នាតធំនៅក្នុងតំបន់ទន្លេមេគង្គ

រៀបរៀងដោយៈ ហ្សាលម៉ាលី ហ្គូត្តាល់ (Shalmali Guttal)
និង ច្រឹក សុភា (Sophea Chrek)

FOCUS ON THE GLOBAL SOUTH | ខែធ្នូ ឆ្នាំ២០១៦



Published by

FOCUS ON THE GLOBAL SOUTH

ROSA LUXEMBURG STIFTUNG
SOUTHEAST ASIA

Published with the support of Rosa-Luxemburg Stiftung with financial means of the Federal Ministry of Economic Cooperation and Development.

Not for Sale

Cover: Dam on Nam Ou river, Lao PDR, 2014.
Photo credit: Michael Dwyer

# មាតិកា


4 សេចក្តីផ្តើម

6 ការដេញតាមមូលធនវិនិយោគ

12 ទម្រង់បែបបទក្របខ័ណ្ឌការងារថ្នាក់តំបន់ និងសកលលោក

17 តំបន់សេដ្ឋកិច្ចពិសេស (SEZs)

20 ផលប្រយោជន៍របស់វិនិយោគិនមុនសិទ្ធិប្រជាជននិងធម្មជាតិ

23 ឧបសម្ព័ន្ធ

26 Notes

# សេចក្តីផ្តើម

*«ការវិនិយោគគឺវាមិនអាក្រក់ណាស់ណានោះទេ។ វាអាស្រ័យទៅលើប្រភេទនៃការវិនិយោគដែលយើងលើកយកមកនិយាយ។ តើវាគឺជាប្រភេទវិនិយោគ ដែលអនុញ្ញាតឲ្យវិស័យឯកជនគ្រប់គ្រងទាំងស្រុងលើសិទ្ធិមូលដ្ឋានរបស់ពួកយើងក្នុងទទួលបាននូវសេវាបឋមផ្សេងៗដែរឬទេ ឧទាហរណ៍សេវាសុខភាព អប់រំ ទឹកភ្លើងជាដើម? ឬក៏យើងនិយាយអំពីការវិនិយោគរបស់រដ្ឋ ក្នុងការធ្វើឲ្យប្រសើរឡើងនូវសេវាសាធារណៈ ដែលមានគោលបំណងបម្រើដល់ប្រជាពលរដ្ឋភាគច្រើនក្នុងចំណោមពួកយើងទាំងអស់គ្នានេះ?»*

លី ពិសី (Pisey Ly) អ្នកគាំទ្របច្ចេកទេសដល់បណ្តាញពហុវិស័យកម្ពុជា។[1]

*«អំណោយទានពីធម្មជាតិ និងធនធានមនុស្សដ៏សម្បូរបែបនៅក្នុងតំបន់ទន្លេមេគង្គ បានប្រែក្លាយតំបន់នេះឲ្យទៅជាតំបន់ឈានមុខគេនៃកំណើនសេដ្ឋកិច្ចអាស៊ី។ ជាការពិតណាស់ តំបន់ទន្លេមេគង្គ មានសក្តានុពលក្លាយជាតំបន់មួយដែលមានភាពរីកចម្រើនលឿនជាងគេបំផុតនៅលើពិភពលោក។»*

ធនាគារអភិវឌ្ឍន៍អាស៊ី[2]

នៅក្នុងតំបន់ទន្លេមេគង្គទាំងមូលពាក្យ «អភិវឌ្ឍន៍» បានក្លាយទៅជាពាក្យដែលមានន័យថានៃកំណើនសេដ្ឋកិច្ច ដែលការ

Rice field of Battambang province, Cambodia, 2016. Photo credit: Ridan Sun



# ទិដ្ឋភាពទូទៅនៃវិនិយោគខ្នាតធំនៅក្នុងតំបន់ទន្លេមេគង្គ

អភិវឌ្ឍនេះអាចសម្រេចទៅបានដោយផ្តោតទៅលើការវិនិយោគឯកជនទ្រង់ទ្រាយធំ។ រដ្ឋាភិបាលនៅក្នុងតំបន់នេះបានលើកកម្ពស់គំរូនៃការអភិវឌ្ឍបែបនេះ ហើយបានចាត់អាទិភាពលើការធ្វើពាណិជ្ជកម្ម និងការវិនិយោគបែបសេរីភាវូបនីយកម្ម។ ការវិនិយោគឯកជនត្រូវបានមើលឃើញថាមាននៅស្ទើរគ្រប់វិស័យទាំងអស់នៃសេដ្ឋកិច្ច រាប់តាំងពីវិស័យថាមពល ប្រេង រ៉ែ កសិកម្ម និងការកែច្នៃចំណីអាហារ រហូតដល់វិស័យអប់រំ សុខាភិបាល ទេសចរណ៍ ផលិតកម្ម ឱសថកម្ម ដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធក្នុងទីក្រុង។ ឯកសារនេះបង្ហាញពីទិដ្ឋភាពទូទៅនៃនិន្នាការរបស់ការវិនិយោគទាំងនេះនៅក្នុងតំបន់ទន្លេមេគង្គ ពីការផ្លាស់ប្តូរច្បាប់ និងគោលនយោបាយដែលបានធ្វើឡើងដើម្បីសម្របសម្រួលដល់ការវិនិយោគខ្នាតធំរបស់អន្តរជាតិនិងក្នុងស្រុក និងបង្ហាញពីផលប៉ះពាល់នៃការវិនិយោគបែបនេះទៅលើតំបន់សេដ្ឋកិច្ចពិសេស (SEZs) ជាពិសេសទៅលើលក្ខខណ្ឌរស់នៅ និងលក្ខខណ្ឌការងាររបស់កម្មករ នៅក្នុងតំបន់សេដ្ឋកិច្ចពិសេសទាំងនេះ។ ឯកសារនេះផ្តល់នូវការវិភាគបែបស៊ីជម្រៅមួយទៅលើទំហំ និងប្រភេទផ្សេងៗនៃការវិនិយោគខ្នាតធំនៅក្នុងតំបន់ ហើយនឹងពីរបៀបដែលការវិនិយោគទាំងនេះធ្វើឲ្យវិនិយោគិនខ្នាតធំមានបុព្វសិទ្ធិ(សិទ្ធិពិសេស) ជាងប្រជាជនក្នុងស្រុក និងលុបលើផលប្រយោជន៍សាធារណៈ។

ក្នុងអំឡុងពេលជាងពីរទសវត្សរ៍កន្លងទៅនេះ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ (IFIs) ជាពិសេសធនាគារអភិវឌ្ឍន៍អាស៊ី (ADB) នឹងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) និងរដ្ឋាភិបាលនៅក្នុងតំបន់បានលើកកម្ពស់តំបន់ទន្លេមេគង្គឲ្យក្លាយទៅជាតំបន់គោលដៅមួយដែលមានអំណោយផលនិងគួរជាទីពេញចិត្តសម្រាប់ការដាក់វិនិយោគទុន ដោយសន្យាជាមួយនឹងវិនិយោគិនខ្នាតធំក្នុងការទទួលបានយ៉ាងងាយស្រួលនូវដីធ្លី ទឹក រ៉ែ និងកម្លាំងពលកម្ម ប្រកបដោយសុខសុវត្ថិភាព ហើយពួកគេអាចមានសេរីភាពគេចផុតពីការអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិនានាដែលអាចប៉ះពាល់ដល់ប្រាក់ចំណូលរបស់ពួកគេ។ មិនតែប៉ុណ្ណោះពួកគេថែមទាំងទទួលបាននូវការការពារពីបាតុកម្ម កូដកម្ម និងការទទូចទាមទារតវ៉ាផ្សេងៗពីកម្មករ និងប្រជាជនក្នុងស្រុកផងដែរ។ វិនិយោគិនខ្នាតធំមានការចាប់អារម្មណ៍ណាស់ចំពោះការសន្យាលើការទទួលបាននូវវត្ថុធាតុដើម តម្លៃពលកម្មថោក អត្រាបង់ពន្ធទាប ការធានាឲ្យមានទីផ្សារ និងការការពារពីច្បាប់។ រដ្ឋាភិបាលទាំងអស់នៅក្នុងតំបន់ កំពុងតែបង្កើនប្រជាប្រិយភាពដោយបង្កើតច្បាប់ធូររលុងចំពោះការធ្វើវិនិយោគ និងផ្តល់នូវការលើកទឹកចិត្តដើម្បីទាក់ទាញទាំងវិនិយោគិនក្នុងស្រុកនិងទាំងវិនិយោគិនបរទេស។ វិនិយោគទុនសាធារណៈលើទំនិញនិងសេវាកម្ម ដែលចាំបាច់ក្នុងការធានាឲ្យមាននូវសុខមាលភាពប្រជាជនភាគច្រើនដូចជាសេវាសុខាភិបាល អប់រំ ទឹកស្អាត និងអនាម័យ សេវាដឹកជញ្ជូន ការការពារ ការធានារ៉ាប់រងប្រឆាំងនឹងគ្រោះធម្មជាតិនានាជាដើម ក៏ត្រូវបានដាក់ទៅក្នុងក្របខ័ណ្ឌការងារក្នុងរូបភាពភាពជាដៃគូរវាងសាធរណៈ និងឯកជនដែរ (PPPs)។

ឈ្មោះតំបន់ទន្លេមេគង្គ បានមកពីឈ្មោះរបស់ទន្លេមេគង្គ ដែលហូរកាត់ខេត្តយូណាននៃសាធារណរដ្ឋប្រជាមានិតចិន (ប្រទេសចិន) សហភាពមីយ៉ាន់ម៉ា (ប្រទេសមីយ៉ាន់ម៉ា) ព្រះរាជាណាចក្រថៃ (ប្រទេសថៃ) សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ (ប្រទេសឡាវ) ព្រះរាជាណាចក្រកម្ពុជា (ប្រទេសកម្ពុជា) និងសាធារណរដ្ឋសង្គមនិយមវៀតណាម (ប្រទេសវៀតណាម)។ ទន្លេមេគង្គ គឺជាទន្លេដែលវែងជាងគេលំដាប់ទី១២ នៅលើពិភពលោក ហើយវាហូរកាត់ផ្ទៃដីសរុបនៅក្នុងប្រទេសទាំងប្រាំមួយនេះ ចំនួនប្រហែលជា ៧៩៥.០០០គីឡូម៉ែត្រការេតាមរយៈការហូរចាក់ចេញទៅជាបណ្តាញយ៉ាងធំមួយដែលមានដៃទន្លេជាច្រើន។ ដៃទន្លេទាំងនោះ បង្កើតចេញទៅជាកូនអាងស្តុកទឹកធម្មជាតិជាច្រើនកន្លែង។ ទន្លេនេះមានប្រភពដើមមកពីតំបន់ខ្ពង់រាបព្រិលទឹកកកនៃតំបន់គីងហៃយ៍ទីបេ ហូរចាក់តាមសណ្ឋានដីដែលមានទ្រង់ទ្រាយផ្សេងៗគ្នា រួមបញ្ចូលទាំងហូរកាត់តំបន់ខ្ពង់រាបទីបេ តំបន់ទន្លេបី និងអាងស្តុកទឹកឡានចាង ដែលបានបង្កើតចេញជាអាងស្តុកទឹកទន្លេមេគង្គលើ និងហូរកាត់តាមតំបន់ខ្ពង់រាបខាងជើង ខ្ពង់រាបខូរ៉ាត អាងស្តុកទឹកបឹងទន្លេសាប និងតំបន់ដីសណ្តទន្លេមេគង្គ ហើយបានបង្កើតចេញជាអាងស្តុកទឹកទន្លេមេគង្គក្រោម។[3]

តំបន់នេះល្បីខាងសម្បូរទៅដោយបរិយាកាស សង្គម វប្បធម៌ ជីវៈចម្រុះ និងបរិស្ថានដែលមានលក្ខណៈសម្បូរបែប។ រាប់តាំងពីទឹក ឈើ រុក្ខជាតិ សត្វព្រៃ ត្បូងថ្មមានតម្លៃ និងធនធានរ៉ែផ្សេងៗ ដែលសម្បត្តិធម្មជាតិនៅក្នុងតំបន់ទាំងនេះបានផ្តល់នូវមូលដ្ឋានគ្រឹះដ៏រឹងមាំមួយសម្រាប់សេដ្ឋកិច្ចដ៏សម្បូរបែបនៅមូលដ្ឋាន និងក្នុងស្រុក។ លំនាច់ និងលំហូរទឹកទន្លេមេគង្គនិងដៃទន្លេមេគង្គនៅចន្លោះរដូវប្រាំង និងវស្សាបានជួយដល់ប្រព័ន្ធអេកូឡូស៊ីរបស់បឹងបួ ស្ទឹងទន្លេ វាលល្បាប់ដីទំនាប និងតំបន់ដែលមិនសម្បូរចរន្តទឹកហូរឲ្យសម្បូរទៅដោយជីវៈចម្រុះ ដូចជានៅបឹងទន្លេសាបរបស់កម្ពុជា និងនៅតំបន់ដីសណ្តទន្លេមេគង្គរបស់វៀតណាម ដែលស្ថិតនៅអាងក្នុងស្តុកទឹកទន្លេមេគង្គក្រោម។ ទន្លេមេគង្គ ត្រូវបានចាត់ទុកថាជាទន្លេទីពីរបន្ទាប់ពីទន្លេអាម៉ាហ្សូន ក្នុងន័យថាសម្បូរទៅដោយជីវៈចម្រុះធម្មជាតិ និងជាជម្រកដ៏ធំជាងគេបំផុតនៅលើពិភពលោករបស់ពពួកត្រីទឹកសាប ហើយនឹងជួយផ្គត់ផ្គង់ដល់ជីវភាពរស់នៅរបស់ប្រជាជនយ៉ាងតិច ៦០លាននាក់ផងដែរ។[4] ការប្រែប្រួលនៃទន្លេមេគង្គ ឬដៃទន្លេរបស់វា ជាលទ្ធផលអាចបណ្តាលឲ្យមានការផ្លាស់ប្តូរដ៏គួរឲ្យកត់សម្គាល់ទៅលើបរិស្ថាន និងសេដ្ឋកិច្ចរបស់តំបន់ទាំងមូល។

មានប្រជាជនប្រហែលជា៣២៩លាននាក់ កំពុងរស់នៅក្នុងតំបន់ទន្លេមេគង្គ[5] ក្នុងនោះមានប្រជាជនជាង១៣៦លាននាក់ធ្វើការងារលក់កម្លាំងពលកម្ម[6] និងក្នុងនោះមានជនជាតិភាគតិចជាង៧០ជនជាតិផ្សេងៗគ្នា និងមានភាសាផ្សេងៗគ្នាស្ថិតនៅពាសពេញប្រទេសទាំងអស់ដែលនៅក្នុងតំបន់នេះ។ ប្រជាជនប្រហែលជា៨០ភាគរយ មានជីវភាពរស់នៅដោយពឹងផ្អែកអាស្រ័យផលលើកសិកម្មខ្នាតតូច និងការនេសាទតាមបែបបុរាណ(ផ្ទាល់ដៃ)។ សាច់ត្រីបានផ្តល់នូវប្រភព នៃប្រូតេអ៊ីនជាងពាក់កណ្តាលលើតម្រូវការប្រូតេអ៊ីនទាំងអស់ដល់ប្រជាជននៅក្នុងតំបន់។ តំបន់នេះផងដែរ ក៏ជាតំបន់ដែលមានការអនុវត្តកសិកម្មដ៏អស្ចារ្យតាមវិធីសាស្ត្រប្លែកៗគ្នា ហើយក៏ជាតំបន់ដែលមានធនធានដី ព្រៃឈើ និងវិធីសាស្ត្រគ្រប់គ្រងថែរក្សាធនធានទឹកដ៏អស្ចារ្យផងដែរ ដែលវិធីសាស្ត្រជាច្រើនបានវិវឌ្ឍចេញពីការអនុវត្តបែបប្រពៃណីដែលកើតមានជាយូរលង់ណាស់មកហើយ និងចេញពីចំណេះដឹងនៅក្នុងស្រុក។ ទាំងនេះរួមបញ្ចូលទាំងប្រព័ន្ធធារាសាស្ត្រ (ប្រព័ន្ធស្រោចស្រព) បែបបុរាណ ការធ្វើស្រែតាមជំរាលភ្នំនៅតំបន់ខ្ពង់រាប ការដាំស្រូវលិចទឹក ការធ្វើចម្ការតាមមាត់ទន្លេ ការធ្វើស្រែប្រាំង និងការនេសាទតាមរដូវ។ ជាទូទៅ សហគមន៍ដាច់ស្រយាលបំពេញតម្រូវការស្បៀងអាហារ និងប្រាក់ចំណូលរបស់ពួកគេតាមរយៈស្រូវអង្ករ ឈើ និងដំណាំផ្សេងៗ ការប្រមាញ់សត្វ ការនេសាទ និងការស្វែងរកចំណីអាហារ។ ដីស្រែ ព្រៃឈើ ដីព្រៃ ដីទំនាប ទន្លេ/ស្ទឹង បឹងបួ និងតំបន់ខ្ពង់រាប គឺជាប្រភពនៃចំណីអាហាររុក្ខជាតិគឺប្រើសម្រាប់ជាឱសថ ផ្ទះសម្បែង និងឧបករណ៍សម្រាប់បំពេញការងារនានា ហើយវាព្រមទាំងជាប្រភពនៃអនុផលព្រៃឈើ (NTFPs) ដ៏សំខាន់សម្រាប់ប្រជាជនដែលរស់នៅក្នុងតំបន់ដាច់ស្រយាល។

ប្រទេសនានានៅក្នុងតំបន់នេះមានស្ថានភាពសេដ្ឋកិច្ចខុសៗគ្នា។ ប្រទេសមីយ៉ាន់ម៉ា ឡាវ និងកម្ពុជាត្រូវបានចាត់ចូលទៅក្នុងប្រភេទប្រទេសដែលមានការអភិវឌ្ឍតិចតួច (LDCs) ហើយដែលមានទំហំសេដ្ឋកិច្ចតូចបំផុត បើមើលលើផលិតផលសរុបក្នុងស្រុក (GDP) នៃចំណូលរបស់បុគ្គលម្នាក់ៗ ប៉ុន្តែពួកគេមានធនធានធម្មជាតិ និងសម្បត្តិបរិស្ថានច្រើនជាងប្រទេសជិតខាងដែលធំៗជាងពួកគេទៅទៀត។ ប្រទេសថៃអាចនិយាយបានថា ជាប្រទេសដែលមានជាងគេបំផុត បើមើលទៅលើប្រាក់ចំណូល ការប្រើប្រាស់ និងសកម្មភាពសេដ្ឋកិច្ចនៅក្នុងតំបន់នោះ។ ប្រទេសចិន ថៃ និងវៀតណាមបានធ្វើការវិនិយោគក្នុងស្រុកសំខាន់ៗទៅលើវិស័យសុខាភិបាល អប់រំ សេវាមូលដ្ឋាន និងសេវាហិរញ្ញវត្ថុ វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា និងការអភិវឌ្ឍកម្លាំងពលកម្ម។ ប៉ុន្តែប្រទេសមីយ៉ាន់ម៉ា ឡាវ និងកម្ពុជានៅតែបន្តទទួលបាននូវពិន្ទុទាបលើសូចនាករសង្គម ដោយសារតែការវិនិយោគសាធារណៈរបស់ជាតិទៅលើវិស័យសង្គមកិច្ចសំខាន់ៗ នៅមានចំនួនតិចតួចប៉ុណ្ណោះ។ អ្នកធ្វើគោលនយោបាយនៅក្នុងប្រទេសទាំងបីនេះ ហាក់ដូចជារំពឹងទុកថាភាពទាក់ទាញយ៉ាងសម្បើមពីការវិនិយោគផ្ទាល់ពីបរទេស (FDI) នឹងបង្កើតនូវលក្ខខណ្ឌទាមទារមួយចំនួន ដែលនឹងធ្វើឲ្យសូចនាករសេដ្ឋកិច្ចសង្គមមានភាពល្អប្រសើរឡើង នៅក្នុងរយៈពេលខ្លី ហើយដែលនាំឲ្យប្រទេសរបស់ពួកគេឆ្លងផុតចេញពីចំណាត់ថ្នាក់ប្រទេសដែលមានការអភិវឌ្ឍតិចតួចទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យម។

# ការដេញតាមមូលធនវិនិយោគ

ខណៈដែលរដ្ឋាភិបាលទាំងអស់នៅក្នុងតំបន់ទន្លេមេគង្គស្វែងរកនូវការវិនិយោគទុនផ្ទាល់ពីបរទេស ប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម (CLMV) គឺជាប្រទេសដែលមានភាពទាក់ទាញជាពិសេសចំពោះវិនិយោគិនបរទេស ពីព្រោះតែសម្បត្តិធនធានធម្មជាតិ និងកម្លាំងពលកម្មវ័យក្មេងរបស់ពួកគេ ដែលអាចទាញយកមកចាត់ចែងរៀបចំដាក់ចូលទៅក្នុងសង្វាក់ផលិតកម្មសកល (GVC) បាន។ នៅក្នុងឆ្នាំ២០១៥ លំហូរនៃវិនិយោគទុនផ្ទាល់ពីបរទេសទៅក្នុងប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាមបានកើនឡើងចំនួន៣៨ភាគរយ (១៧,៩លានដុល្លារ)។ ចន្លោះពីឆ្នាំ២០១៤ និង២០១៥ ការវិនិយោគទុនបានកើនឡើងកម្រិតមធ្យមទៅលើផ្នែកផលិតកម្ម ហិរញ្ញវត្ថុនិងហេដ្ឋារចនាសម្ព័ន្ធទោះបីជាវាមិនដូចគ្នាក្តីនៅតាមប្រទេសនីមួយៗ។[7]

លំហូរនៃការវិនិយោគទុនផ្ទាល់ពីបរទេសទៅប្រទេសនានានៅក្នុងតំបន់ទន្លេមេគង្គ បានដាក់ការវិនិយោគទៅលើវិស័យផ្សេងៗគ្នាមួយចំនួន ដូចជាធនធានអភិវឌ្ឍន៍លើថាមពលនិងឧស្សាហកម្មរុករករ៉ែ (ប្រេង ឧស្ម័ន ធ្យូងថ្ម សារធាតុរ៉ែ រ៉ែ ទំនប់វារីអគ្គីសនី ប្រព័ន្ធបញ្ជូនថាមពលអគ្គីសនី) ទៅលើវិស័យព្រៃឈើ កសិកម្ម ដីនិងទឹក ផលិតកម្ម ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន (ផ្លូវថ្នល់ ផ្លូវធំល្បឿន (ហៃវេយ៍) ផ្លូវដែក ផែនិងកំពង់ផែសមុទ្រទឹកជ្រៅ និងព្រលានយន្តហោះ) សេវាកម្ម (ហិរញ្ញវត្ថុ ធនាគារ មន្ទីរពេទ្យ អប់រំ ទឹកស្អាតនិងអនាម័យ) ទេសចរណ៍ អចលនទ្រព្យ/ដីធ្លីនិងការអភិវឌ្ឍទីក្រុង (ផ្ទះថ្លៃទំនើប ផ្ទះបុរី ក្លឹបកីឡា សណ្ឋាគារ រមណីយដ្ឋាន ការដឹកជញ្ជូន អគារផ្សារធំទំនើប និងបនល្បែង (កាស៊ីណូ)) ទូរគមនាគមន៍និងបច្ចេកវិទ្យា តំបន់ឧស្សាហកម្ម (IZs) តំបន់សេដ្ឋកិច្ចពិសេស (SEZs) និងតំបន់កែច្នៃសម្រាប់នាំចេញ (EPZs)។



A local employee of Stora Enzo Company leaning against a pile of eucalyptus trees inside the commercial plantation setting up in the village of Ban Lapeung, Ta-oy district, Salavan province, Lao PDR.
Photo credit: Anthony Gueguen/CCL

កម្រិតនៃការវិនិយោគទុនផ្ទាល់ពីបរទេស គឺខុសៗគ្នាទៅតាមប្រទេសនីមួយៗ ដោយវាអាស្រ័យទៅលើច្បាប់ និងបទប្បញ្ញត្តិក្នុងស្រុក ការលើកទឹកចិត្ត និងភាពទាក់ទាញរបស់ខ្លួន ដែលមានសម្រាប់សង្វាក់ផលិតកម្មនៅក្នុងតំបន់និងសកលលោក។ មួយវិញទៀត ការវិនិយោគគឺមិនមែនសុទ្ធតែមកពីបរទេសនោះទេ ព្រោះក៏មានការវិនិយោគក្នុងស្រុកហើយនិងសហគ្រាសឯកជនរបស់រដ្ឋផងដែរ។ មានគម្រោងអភិវឌ្ឍន៍ជាច្រើន ដែលផ្តោតលើវិស័យហេដ្ឋារចនាសម្ព័ន្ធថាមពល និងការរុករករ៉ែ ហើយវាគឺជាគម្រោងកម្មវិធីបែបភាពជាដៃគូរវាងរដ្ឋនិងឯកជន ដែលមានសមាសភាពជាសហគ្រាសរដ្ឋខ្លួនឯងផ្ទាល់ ជាសាជីវកម្មរបស់ក្រុមឧកញ៉ាៗ ឬអ្នកមានៗក្នុងស្រុក និងជាកម្មសិទ្ធិរបស់វិនិយោគិនបរទេសពោលគឺវាអាចជាគម្រោងរបស់សហគ្រាសរដ្ឋ ឬក៏សាជីវកម្មឯកជន។ នៅកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា ការវិនិយោគទុនផ្ទាល់ពីបរទេសទៅលើវិស័យកសិកម្ម ធ្វើអោយមានការទទួលបាននូវសម្បទានដី ក្រោមកិច្ចសន្យាជួលដីរយៈពេលវែង (រហូតដល់ទៅ៩៩ឆ្នាំ) ហើយជួលនៅក្នុងតម្លៃទាប ដែលដីសម្បទាននោះត្រូវបានប្រើប្រាស់សម្រាប់ដាំដំណាំមួយចំនួន ដូចជាកៅស៊ូ ពោតអំពៅ និងដំឡូងមី ដែលទិន្នផលនៃដំណាំទាំងនេះត្រូវបានយកទៅកែច្នៃជាចំណីអាហារ ឬក៏ជាផលិតផលឧស្សាហកម្ម។[8]

តំបន់ទន្លេមេគង្គ ជាពិសេសប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម កំពុងតែបង្កើត អនុម័ត និងកែតម្រូវច្បាប់ គោលនយោបាយ នីតិវិធី បទប្បញ្ញត្តិ និងស្ថាប័នក្នុងស្រុក ដើម្បីជាការលើកទឹកចិត្ត និងការការពារសម្រាប់វិនិយោគិន ហើយនឹងបង្កើតឲ្យមាននូវបរិយាកាសគាំទ្រដល់ការវិនិយោគខ្នាតធំថែមទៀតផង។ ទាំងនេះរួមបញ្ចូលទាំងការបង្កឲ្យមានភាពងាយស្រួលដល់វិនិយោគិនផងដែរ ដូចជា «សេវាច្រកចេញចូលតែមួយ» សម្រាប់សម្រួលដល់នីតិវិធីដាក់បែបបទសុំធ្វើការវិនិយោគ និងសុំអាជ្ញាប័ណ្ណ ព្រមទាំងមានលក្ខខណ្ឌដែលគាំទ្រដល់ការការពារវិនិយោគ សមធម៌សម្រាប់វិនិយោគិនបរទេស ពន្ធអាករ ការប្តូរប្រាក់បរទេស ការរឹបអូសដីធ្លីពីប្រជាជនមូលដ្ឋាន ការយកកម្មករបរទេសមកធ្វើការ និងភាពជាម្ចាស់កម្មសិទ្ធិលើដី/អគារ និងនៅមានលក្ខខណ្ឌច្រើនជាងនេះទៀត។ ជាទូទៅការធ្វើកំណែទម្រង់ច្បាប់

គឺត្រូវឲ្យស្របជាមួយនឹងបទដ្ឋាន និងស្តង់ដារពាណិជ្ជកម្ម និងការវិនិយោគអន្តរជាតិដើម្បីសម្រេចឲ្យបានតាម លក្ខខណ្ឌនៃកិច្ចព្រមព្រៀងវិនិយោគពាណិជ្ជកម្មសេរីដែលប្រទេសនៅក្នុងតំបន់ទន្លេមេគង្គបានចូលរួមជាមួយ។

ការវិនិយោគដោយផ្ទាល់ពីបរទេសលើសេវាកម្ម បានរួមចំណែកដល់ទៅជិតពាក់កណ្តាលនៃផលទុនជាតិសរុប (GDP) នៃប្រទេសនៅក្នុងតំបន់ទន្លេមេគង្គក្នុងឆ្នាំ២០១៥។ ការចូលរួមចំណែកក្នុងផលទុនជាតិសរុប ពីវិនិយោគលើវិស័យឧស្សាហកម្ម ក៏ត្រូវបានមើលឃើញថាមានចំនួនច្រើនគួរសមដែរ។ (សូមមើលតារាង ១) ទោះបីជាដូចនេះក៏ដោយ ក៏កំណើនវិនិយោគទុនលើវិស័យនីមួយៗ និងការរួមចំណែករបស់វាទៅក្នុងកំណើននៃផលទុនជាតិសរុប ពុំត្រូវបានយល់ឃើញថាបានជួយកាត់បន្ថយវិសមភាពទ្រព្យសម្បត្តិ (គម្លាតរវាងអ្នកមាននិងអ្នកក្រ) និងភាពមិនស្មើគ្នានៃការទទួលបាន និងការគ្រប់គ្រងលើធនធាននានានោះទេ ដែលនេះគឺនៅតែស្ថិតក្នុងកណ្តាប់ដៃរបស់ក្រុមអ្នកមានអំណាច និងបក្សពួករបស់គេ របស់សាជីវកម្ម និងរបស់អ្នកនយោបាយមួយចំនួន។

## តារាង ១៖ ចំនួនវិនិយោគទុនដែលបូកចូលទៅក្នុងផលិតផលក្នុងស្រុកសរុប (GDP) ក្នុងឆ្នាំ២០១៥

| Country | Investment by sectors | Percentage of GDP |
|---|---|---|
| កម្ពុជា | កសិកម្ម | ២៨,២% |
| | ឧស្សាហកម្ម | ២៩,៤% |
| | សេវាកម្ម | ៤២,៣% |
| ឡាវ* | កសិកម្ម | ២៤,៨% |
| | ឧស្សាហកម្ម | ៣៤,៧% |
| | សេវាកម្ម | ៤០,៥% |
| មីយ៉ាន់ម៉ា | កសិកម្ម | ២៦,៧% |
| | ឧស្សាហកម្ម | ៣៤,៥% |
| | សេវាកម្ម | ៣៨,៧% |
| ថៃ | កសិកម្ម | ៩,១% |
| | ឧស្សាហកម្ម | ៣៥,៧% |
| | សេវាកម្ម | ៥៥,១% |
| វៀតណាម | កសិកម្ម | ១៨,៩% |
| | ឧស្សាហកម្ម | ៣៧,០% |
| | សេវាកម្ម | ៤៤,២% |

ប្រភព៖ ធនាគារអភិវឌ្ឍន៍អាស៊ី។ ទស្សនៈវិស័យនៃការអភិវឌ្ឍនៅអាស៊ី៖ សក្តានុពលនៃកំណើនសេដ្ឋកិច្ចនៅអាស៊ី។ ឆ្នាំ២០១៦។ ធនាគារអភិវឌ្ឍន៍អាស៊ី។ តារាងសូចនាករសំខាន់ៗតាមប្រទេសសម្រាប់អាស៊ីនិងប៉ាស៊ីហ្វិចឆ្នាំ២០១៦
ចំណាំ៖ *ទិន្នន័យរបស់ធនាគារអភិវឌ្ឍន៍អាស៊ីអំពីប្រទេសឡាវ គឺអាចរកបានតែសម្រាប់ឆ្នាំ២០១៤ប៉ុណ្ណោះចំពោះសូចនាករសំខាន់ៗសម្រាប់អាស៊ីនិងប៉ាស៊ីហ្វិចឆ្នាំ២០១៦។

# កម្ពុជា

ការវិនិយោគឯកជននៅក្នុងប្រទេសកម្ពុជាគឺមាននៅក្នុងវិស័យមួយចំនួន រាប់តាំងពីវិស័យកសិឧស្សាហកម្ម ដល់ការធ្វើពាណិជ្ជកម្មប្រកបដោយយុត្តិធម៌លើកសិកម្មខ្នាតតូច និងហាងជួសជុលផ្សេងៗនៅតាមផ្លូវ។[9] វិស័យចម្បងៗទាំងបីរួមមាន វិស័យសេវាកម្ម វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងវិស័យឧស្សាហកម្ម។ ទាំងនេះគឺជាវិស័យដែលរួមចំណែកយ៉ាងសំខាន់ដល់ផលិតផលក្នុងស្រុកសរុប (GDP) ឆ្នាំ២០១៥ វិស័យសេវាកម្មមាន៤២ភាគរយ វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមាន២៨ភាគរយ ហើយនិងវិស័យឧស្សាហកម្មមាន២៩ភាគរយ។[10] វិស័យអាទិភាពផ្សេងៗទៀតសម្រាប់វិនិយោគមាន ថាមពល ការរុករករ៉ែ ហិរញ្ញវត្ថុ ធនាគារ ហេដ្ឋារចនាសម្ព័ន្ធ និងបច្ចេកវិទ្យា។ យោងតាមគេហទំព័ររបស់រដ្ឋាភិបាលកម្ពុជា ការបូកសរុបតម្លៃគម្រោងវិនិយោគទុនផ្ទាល់ពីបរទេសពីឆ្នាំ១៩៩៤ដល់ឆ្នាំ២០១៤ គឺភាគហ៊ុនដែលធំជាងគេគឺមកពីប្រទេសចិន (២៣,៩៧ ភាគរយ) បន្ទាប់មកគឺកូរ៉េខាងត្បូង (១០,៦៨ ភាគរយ)។ ការវិនិយោគទុនផ្ទាល់ពីបរទេសដែលមកពីប្រទេសម៉ាឡេស៊ី តៃវ៉ាន់ ហុងកុង និងថៃគឺគួរឲ្យកត់សម្គាល់ខ្លាំងណាស់ ជាពិសេសនៅក្នុងវិស័យឧស្សាហកម្មកាត់ដេរ។ ការវិនិយោគទុនពីបរទេស បានកើនឡើង ប្រមាណជា១,៨កោដិដុល្លារអាមេរិក នៅក្នុងឆ្នាំ២០១៥ ពោលគឺគិតពីត្រឹមឆ្នាំ២០១៤មក អត្រាកំណើនមាន៨ភាគរយ ដែលរួមចំណែក១០ភាគរយទៅក្នុងភាគរយទាំងអស់នៃផលិតផលក្នុងស្រុកសរុប។[11]

គោលនយោបាយសេដ្ឋកិច្ចជាតិរបស់កម្ពុជា បទប្បញ្ញត្តិ និងក្របខ័ណ្ឌវិនិយោគធ្វើឲ្យប្រទេសនេះ ក្លាយទៅជាប្រទេសដែលមានសេដ្ឋកិច្ចសេរីខ្លាំងជាងគេបំផុតនៅក្នុងតំបន់ និងក៏ជាប្រទេសដែលផ្តល់បរិយាកាសអំណោយទានសម្រាប់វិនិយោគិនក្នុងស្រុកនិងបរទេសជាងគេផងដែរ។[12] ការលើកទឹកចិត្តវិនិយោគិនបរទេសដើម្បីទាក់ទាញវិនិយោគទុន រួមមានជនបរទេសមានសិទ្ធិធ្វើជាម្ចាស់ក្រុមហ៊ុន១០០ភាគរយ ទទួលបានការលើកលែងពន្ធសាជីវកម្មរហូតដល់ទៅប្រាំបីឆ្នាំ បន្ទាប់ពីអំឡុងពេលលើកទឹកចិត្តផុតកំណត់ហើយនោះ អត្រាពន្ធសាជីវកម្មគឺមានត្រឹមតែ២០ភាគរយប៉ុណ្ណោះ នាំចូលទំនិញដោយរួចពន្ធ និងគ្មានលក្ខខណ្ឌហាមឃាត់ចំពោះការបង្វែរទុនទៅស្រុកវិញ។ វិនិយោគិនបរទេសក៏អាចដាក់ពាក្យស្នើសុំដីសម្បទានសេដ្ឋកិច្ចបានដែរ។




Administration office of Phnom Penh Special Economic Zone, Cambodia, 2016. Photo credit: Sokunthy Ros

ប៉ុន្តែគម្រោងវិនិយោគទុនទាំងនេះ បានផ្សារភ្ជាប់ជាមួយនឹងការដណ្តើមយកដីធ្លី និងការបណ្តេញចេញចំពោះសហគមន៍មូលដ្ឋាន។ ការដណ្តើមយកដី និងជម្លោះលើដីធ្លី ត្រូវបានកំណត់ថាជាបញ្ហារ៉ាំរ៉ៃនិងសំខាន់នៅកម្ពុជា។[13] ម្យ៉ាងទៀត ដើម្បីធានាឲ្យបាននូវបរិយាកាសពាណិជ្ជកម្មដែលប្រកបដោយសុវត្ថិភាពច្រើនជាងមុនសម្រាប់វិនិយោគិនខ្នាតធំ វិនិយោគិនទាំងនោះមិនត្រូវបានទាមទារឲ្យមានគណនេយ្យភាព ឬគោរពតាមច្បាប់ណាមួយទេចំពោះការបំផ្លាញបរិស្ថាន និងចំពោះសុខមាលភាពរបស់កម្មករក្នុងករណីដែលក្ស័យធន។ កម្មករបានចាប់ផ្តើមធ្វើបាតុកម្មតវ៉ាប្រឆាំងនឹងគោលនយោបាយទាំងនេះ ប៉ុន្តែការឆ្លើយតបរបស់រដ្ឋាភិបាលវិញ បែរជាមានការប្រើនូវកម្លាំងទាហានឬប៉ូលីសបង្ក្រាប ព្រមទាំងបំបាក់ស្មារតីកម្មករនិងសហគមន៍ដែលរងផលប៉ះពាល់អវិជ្ជមានពីគម្រោងវិនិយោគទាំងនេះ។ ឧទាហរណ៍ នៅក្នុងឧស្សាហកម្មកាត់ដេរ កម្មករនៅតែប្រឈមនឹងឧបសគ្គចម្បងៗមួយចំនួន ដូចជាប្រាក់បៀវត្សរ៍ទាប លក្ខខណ្ឌការងារនិងស្ថានភាពរស់នៅមិនល្អ ដែលក្នុងនោះ៨៥ភាគរយនៃកម្មករគឺជាស្ត្រី។ កាលពីឆ្នាំ២០១៤ នៅក្នុងអំឡុងពេលបាតុកម្មមួយនោះកម្មករបួននាក់ត្រូវបានសម្លាប់ យ៉ាងហោចណាស់មានកម្មករ និងអ្នកគាំទ្រចំនួន៣៨នាក់ផ្សេងទៀតបានរងរបួសធ្ងន់ធ្ងរដោយសារតែកងកម្លាំងសន្តិសុខរបស់រដ្ឋាភិបាល។ ក្មេងប្រុសម្នាក់បានបាត់ខ្លួន ហើយកម្មករចំនួន២៣នាក់ត្រូវបានចាប់ខ្លួននៅពេលនោះ។ មានថ្នាក់ដឹកនាំសហជីពក្នុងស្រុកជាច្រើននាក់ក៏បានទទួលរងនូវការចោទប្តឹងពីសំណាក់ក្រុមហ៊ុនដែរ នៅក្នុងអំឡុងពេលដែលមានបាតុកម្មរបស់កម្មករផ្ទុះឡើងនៅពាសពេញផ្ទៃប្រទេស ដើម្បីទាមទារឲ្យមានការដំឡើងប្រាក់ខែគោលនៅក្នុងឆ្នាំ២០១៤[14]។ យ៉ាងហោចណាស់មានសកម្មជនបរិស្ថានបីនាក់ ដែលបានចូលរួមក្នុងបាតុកម្មប្រឆាំងនឹងសេរីភាវូបនីយកម្មវិនិយោគ ត្រូវបានចាប់ដាក់គុកក្នុងឆ្នាំ២០១៥។[15] សហជីពកម្មករក្នុងស្រុក ថ្នាក់ដឹកនាំ/អ្នកតំណាងសហគមន៍ និងសកម្មជនដទៃទៀត ដែលបានទាមទារឲ្យមានយុត្តិធម៌ គណនេយ្យភាព និងសមធម៌ ត្រូវបានមើលឃើញថាជាអ្នកប្រឆាំងនឹងការអភិវឌ្ឍរបស់រដ្ឋាភិបាល។

## មីយ៉ាន់ម៉ា

ការវិនិយោគផ្ទាល់ពីបរទេសនៅក្នុងប្រទេសមីយ៉ាន់ម៉ា គឺផ្តោតសំខាន់លើឧស្សាហកម្មថាមពលអគ្គិសនី និងការទាញយកនូវធនធានធម្មជាតិពីក្នុងដី ដូចជាការរុករករ៉ែ។ ការវិនិយោគទុនផ្ទាល់ពីបរទេសក៏មានទៅលើវិស័យផលិតកម្ម ទូរគមនាគមន៍និងដឹកជញ្ជូន អចលនទ្រព្យ សណ្ឋាគារ ទេសចរណ៍ ការចិញ្ចឹមសត្វ នេសាទ កសិកម្ម សំណង់ ដី និងតំបន់ឧស្សាហកម្ម និងតំបន់សេដ្ឋកិច្ចពិសេស[16]ផងដែរ។ ការវិនិយោគភាគច្រើន បានទទួលការអនុម័តនៅក្នុងការ គ្រប់គ្រងដោយរបបយោធា ក្នុងនោះមានតំបន់សេដ្ឋកិច្ចពិសេសចំនួនបី តំបន់សេដ្ឋកិច្ចពិសេសដាវ៉ែយ៍ (DSEZ) ស្ថិតនៅក្នុងភូមិភាគអាគ្នេយ៍នៃតំបន់តានីនថារីអ៊ី (Tanintharyi) តំបន់សេដ្ឋកិច្ចពិសេសធីឡាវ៉ា (TSEZ) ស្ថិតនៅក្នុងទីក្រុងយ៉ាំងហ្គោន និងតំបន់សេដ្ឋកិច្ចពិសេសចៅឃ្យូ (KPSEZ) ស្ថិតនៅទិសនិរតីនៃរដ្ឋរ៉ាខែង (Rakhine)។[17] មកដល់ត្រឹមខែតុលា ឆ្នាំ២០១៦ វិនិយោគទុនផ្ទាល់ពីបរទេសមកពីប្រទេសចិនទៅក្នុងប្រទេសមីយ៉ាន់ម៉ា មានចំនួន ៣២,៣៧ភាគរយ នៃចំនួនវិនិយោគទុនផ្ទាល់ពីបរទេសសរុបនៅក្នុងប្រទេសនេះ ដែលក្នុងនោះមានគម្រោងចំនួន ១៣៣គម្រោង។ វិនិយោគទុនផ្ទាល់ពីបរទេសមកពីប្រទេសសឹង្ហបូរីមាន២៦,៣៥ភាគរយ ហុងកុង១៣ភាគរយ ហើយនិងថៃមាន៦,១៧ភាគរយ។[18]

រដ្ឋាភិបាលបច្ចុប្បន្នរបស់មីយ៉ាន់ម៉ា បានធ្វើការកែសម្រួលគោលនយោបាយជាច្រើន ដើម្បីធ្វើសេរីភាវូបនីយកម្មសេដ្ឋកិច្ចរបស់គេ នេះរួមបញ្ចូលទាំងការលុបបំបាត់នូវអត្រាប្តូរប្រាក់ជាច្រើន ការកាត់បន្ថយការរឹតបន្តឹងផ្សេងៗលើការធ្វើ ពាណិជ្ជកម្ម ការធ្វើកំណែទម្រង់លើគោលនយោបាយស្តីពីពន្ធដារ និងរដ្ឋបាល ការអនុម័តលើច្បាប់អាជ្ញាកណ្តាលថ្មី ច្បាប់ការងារថ្មី និងច្បាប់ថ្មីស្តីពីការវិនិយោគ ហើយនិងការបន្ធូរបន្ថយលើបន្ទុករដ្ឋបាលមួយចំនួនក្នុងការធ្វើ ពាណិជ្ជកម្មនៅក្នុងប្រទេស។ ទោះបីជាមានអង្គការសង្គមស៊ីវិល (CSOs) ជាច្រើនបានលើកឡើងពីក្តីកង្វល់ អំពីការធ្វើសេរីភាវូបនីយកម្មដោយគំហុកបែបនេះក្តី ក៏ច្បាប់ស្តីពីការវិនិយោគនៅតែត្រូវបានកែតម្រូវឡើងវិញ ហើយបានអនុម័តនៅក្នុងឆ្នាំ ២០១៦។

## ឡាវ

ការវិនិយោគទុនផ្ទាល់ពីបរទេសនៅក្នុងប្រទេសឡាវក្នុងឆ្នាំ២០១៥ បានផ្តោតលើវិស័យចំនួនប្រាំពីរ៖ ថាមពលអគ្គីសនី កសិកម្ម រ៉ែ ឧស្សាហកម្មនិងសិប្បកម្ម សេវាកម្ម កាត់ដេរ និងសណ្ឋាគារ/ភោជនីយដ្ឋាន។ ការវិនិយោគលើថាមពលអគ្គីសនីមានចំនួន៩៩,៩៨ភាគរយនៃចំនួនវិនិយោគទុនផ្ទាល់ពីបរទេសសរុប បន្ទាប់មកគឺវិស័យកសិកម្មមាន ៣៦,៧៦ភាគរយ ការរុករករ៉ែមានចំនួន១៩,៩៩ភាគរយ និងវិស័យឧស្សាហកម្ម និងសិប្បកម្មមាន២,៨៩ភាគយ។[19] នៅក្នុងឆ្នាំដដែលនេះដែរ វៀតណាមមានការវិនិយោគមកលើប្រទេសឡាវច្រើនជាងគេបំផុត ដែលមានគម្រោងចំនួនបី

មានតម្លៃលើសពី៤៦៦ លានដុល្លារអាមេរិកនៃទុនវិនិយោគបន្ទាប់មក គឺប្រទេសម៉ាឡេស៊ីមានពីរគម្រោងដែលមានតម្លៃ ៤៣០លានអាមេរិកដុល្លារនៃទុនវិនិយោគ ហើយនិងប្រទេសចិនមានប្រាំគម្រោងដែលមានតម្លៃ៨៨លានដុល្លារអាមេរិក នៃទុនវិនិយោគ។[20]

រដ្ឋាភិបាលឡាវផ្តល់នូវផលប្រយោជន៍មួយចំនួនដល់វិនិយោគិន ក្នុងស្រុក និងបរទេស ដូចជាសិទ្ធិពិសេសក្នុងការធ្វើពាណិជ្ជកម្មដូចដែលប្រទេសឡាវទទួលបាននៅក្នុងប្រទេសដទៃទៀតដែរ ធនធានធម្មជាតិជាច្រើនដែលមិនទាន់បានយកមកប្រើប្រាស់នៅឡើយ សក្តានុពលនៃវារីអគ្គីសនី ដីកសិកម្មដែលមានទំហំធំ និងមានជីជាតិ អភិវឌ្ឍន៍កន្លែងទេសចរណ៍ផ្សេងៗគ្នា តម្លៃពលកម្មទាប មានស្ថេរភាពសេដ្ឋកិច្ចនយោបាយ និងមានហានិភ័យនយោបាយទាប និងមានសេរីភាពច្បាប់ និងបទប្បញ្ញត្តិដែលបង្កឲ្យមានបរិយាកាសអំណោយផលដល់ការធ្វើពាណិជកម្មនិងវិនិយោគ។ [21] នៅក្នុងតំបន់នេះ ប្រទេសឡាវអាចនិយាយបានជាប្រទេសដែលមានការការពារតិចតួចបំផុតចំពោះប្រជាពលរដ្ឋមូលដ្ឋាន ពីការបំផ្លិចបំផ្លាញដោយគម្រោងវិនិយោគខ្នាតធំ។ ប្រជាជនឡាវពុំបានមានមតិយោបល់អ្វីសោះនៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រទេស ឬក៏ពុំមានច្បាប់គ្រប់គ្រាន់សម្រាប់ពឹងផ្អែកលើដែរ ឬក៏ពុំទទួលបាននូវយុត្តិធម៌ពេលដែលសិទ្ធិរបស់ពួកគេត្រូវបានរំលោភបំពាន ដីរបស់ពួកគេត្រូវបានដណ្តើមយកទៅបាត់ និងបរិស្ថានរបស់ពួកគេត្រូវបានបំពុល។ អ្នកដែលរិះគន់ និងធ្វើបាតុកម្មប្រឆាំងនឹងសកម្មភាពរបស់រដ្ឋាភិបាលត្រូវទទួលរងគ្រោះពីចំណាត់ការយ៉ាងអាក្រក់។

## វៀតណាម

វៀតណាមបានទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស លើសពីតម្លៃ១៣កោដិដុល្លារអាមេរិកទៅទៀត ក្នុងឆ្នាំ២០១២។ មានវិនិយោគទុនផ្ទាល់ពីបរទេសប្រហែលជា១១០០គម្រោងថ្មីទៀត ដែលមានតម្លៃ៧,៨៥កោដិដុល្លារអាមេរិក ត្រូវបានផ្តល់អាជ្ញាប័ណ្ណឲ្យ ហើយមានគម្រោងចំនួន៤៣៥គម្រោង កំពុងតែមានដំណើរការ និងទទួលបានការចុះបញ្ជីវិនិយោគបន្ថែមទៀតដែលមានចំនួន ៥,១៥កោដិដុល្លារអាមេរិក[22]។ ផលិតកម្ម និងការកែច្នៃគឺជាឧស្សាហកម្ម ដែលមានភាពទាក់ទាញខ្លាំងបំផុតសម្រាប់វិនិយោគិនបរទេស ដែលទាញបានការវិនិយោគ ដែលមានតម្លៃសរុបចំនួន ៩,១កោដិដុល្លារអាមេរិក ស្មើនឹង៧០ភាគរយនៃចំនួនទុនសរុប ដែលបានចុះបញ្ជីរួចនៅក្នុងប្រទេស។ ទីពីរគឺវិស័យអចលនទ្រព្យ ដែលមានចំនួន១,៨៥កោដិដុល្លារអាមេរិក ឬ១៤ភាគរយនៃចំនួនទុនដែលបានចុះបញ្ជីរួច រីឯវិស័យលក់រាយ (ចែកចាយ) និងជួសជុលវិញគឺស្ថិតនៅលំដាប់ទីបី ដោយមានតម្លៃ៤៨៣លានដុល្លារអាមេរិក ឬបួនភាគរយនៃទុនដែលបានចុះបញ្ជីរួច។[23]

ក្នុងឆ្នាំ២០១៣ ក្នុងចំណោម៥៨ប្រទេស ជប៉ុនគឺជាប្រភពនៃវិនិយោគទុនផ្ទាល់ពីបរទេសធំជាងគេបំផុតនៅវៀតណាមដែលមានការចុះបញ្ជីទុនថ្មីៗ និងការពង្រីកទុនចំនួន៥,១កោដិដុល្លារអាមេរិក ស្មើនឹង៣៩,៥ភាគរយនៃចំនួនទុនវិនិយោគសរុប។ ប្រទេសសិង្ហបូរីស្ថិតនៅក្នុងលំដាប់ទីពីរ ដែលមានទុនចំនួន១,៧កោដិដុល្លារអាមេរិក បន្ទាប់មកគឺប្រទេសកូរ៉េខាងត្បូង មានទុនចំនួន១,២កោដិដុល្លារអាមេរិក។

ច្បាប់វិនិយោគថ្មីរបស់វៀតណាមត្រូវបានអនុម័តនៅក្នុងឆ្នាំ២០១៤ ហើយបានដាក់ឲ្យអនុវត្តនៅក្នុងឆ្នាំ២០១៥ ដែលនេះបានអនុញ្ញាតឲ្យវិនិយោគិនបរទេស អាចបណ្តាក់ទុនបានលើគ្រប់វិស័យទាំងអស់ លើកលែងតែវិស័យហាមឃាត់ចំនួនប្រាំមួយប៉ុណ្ណោះ ប្រសិនបើវិនិយោគិនយល់ស្របជាមួយនឹងផែនការមេស្តីពីសេដ្ឋកិច្ចរបស់ប្រទេស។ វិនិយោគិនបរទេសបានទទួលការអនុញ្ញាតឲ្យធ្វើវិនិយោគចំនួនប្រាំប្រភេទ ការវិនិយោគរួមគ្នា (JV) កិច្ចព្រមព្រៀងលើកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម (BCC) សហគ្រាសដែលមានជនបរទេសជាម្ចាស់កម្មសិទ្ធិ១០០ភាគរយ (FOEs) ការស្ថាបនាដើម្បីធ្វើការផ្ទេរកិច្ចប្រតិបត្តិការ (BOT) និងការដាក់បញ្ចូលគ្នា និងការទទួលបាន (M&A)។ ច្បាប់ស្តីពីការវិនិយោគនាពេលបច្ចុប្បន្ននេះ ផ្តល់ឲ្យវិនិយោគិនក្នុងស្រុក នឹងបរទេសនូវលក្ខខណ្ឌដូចគ្នា។ វិនិយោគិនបរទេសទទួលបានការលើកលែងចំពោះកាតព្វកិច្ចនាំចូលទំនិញសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន និងទំនិញដែលមិនអាចផលិតនៅក្នុងស្រុកបាន ដូចជាម៉ាស៊ីនផ្សេងៗ រថយន្ត គ្រឿងបន្លាស់របស់ម៉ាស៊ីននិងឧបករណ៍ផ្សេងៗទៀត វត្ថុធាតុដើម ធាតុផ្សំនានាសម្រាប់ធ្វើផលិតកម្ម និងសម្ភារៈសំណង់ដែលមិនអាចផលិតបាននៅក្នុងស្រុក។

តំបន់ទន្លេមេគង្គត្រូវបានផ្សព្វផ្សាយឃោសនាដោយវៀតណាម អូស្ត្រាលី និងអាល្លឺម៉ង់ថាជាទីកន្លែងគោលដៅសំខាន់សម្រាប់ធ្វើវិនិយោគ តាមរយៈកម្មវិធីសមាហរណកម្មលើការគ្រប់គ្រងតំបន់ឆ្នេរសមុទ្រ (ICMP) ដែលអនុវត្តដោយអង្គការជីអាយហ្សិត (GIZ)។ នៅក្នុងការឃោសនាផ្សព្វផ្សាយមួយរបស់កម្មវិធីសមាហរណកម្មលើការគ្រប់គ្រងតំបន់ឆ្នេរសមុទ្រ បានបង្ហាញនូវតារាងមួយស្តីពីមូលហេតុមួយចំនួនដែលគួរតែធ្វើការវិនិយោគនៅក្នុងតំបន់ទន្លេមេគង្គ ធ្វើឲ្យ

សេដ្ឋកិច្ចរីកចម្រើន និងរឹងមាំ បរិយាកាសវិនិយោគគឺល្អអស្ចារ្យ មានបណ្ដាញដឹកជញ្ជូនតភ្ជាប់ដោយផ្ទាល់ និងមានហេដ្ឋារចនាសម្ព័ន្ធដ៏ល្អប្រសើរ មានអ្នកប្រើប្រាស់ចំនួន១៧លាននាក់ មានកម្លាំងពលកម្មខ្លាំងក្លា និងមានបទដ្ឋានសង្គមខ្ពស់ មានការកើនឡើងខ្លាំងលើវិស័យកសិកម្ម និងឧស្សាហកម្មវារីវប្បកម្ម ការប្រែប្រួលអាកាសធាតុដែលក៏ជាឱកាសសម្រាប់ការធ្វើជំនួញមួយផងដែរ និងមានឱកាសជាច្រើនទៀត សម្រាប់ពង្រីកការវិនិយោគនាពេលអនាគត។ រដ្ឋាភិបាលវៀតណាម បានផ្ដល់នូវការលើកទឹកចិត្តជាច្រើនដល់វិនិយោគិនបរទេសទៅតាមវិស័យហើយ នឹងតំបន់ភូមិសាស្ត្រដែលគេចង់បាន ដូចជាពង្រឹងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ដឹកជញ្ជូន សួនឧទ្យានឧស្សាហកម្ម កាត់បន្ថយអត្រាពន្ធលើចំណូលរបស់សាជីវកម្ម (CIT) ការលើកលែងពន្ធ តំបន់សហគ្រាសពិសេស នីតិវិធីស្នើសុំការអនុញ្ញាតនិងអាជ្ញាប័ណ្ណដែលមានភាពងាយស្រួលការលើកលែងពីការជួលដី និងមានគោលនយោបាយមួយចំនួន ដែលជួយកាត់បន្ថយការចំណាយរបស់វិនិយោគិន។ រដ្ឋាភិបាលក៏បានកំណត់នូវប្រាក់ខែគោលយ៉ាងទាបនៅតាមស្រុក ដើម្បីទាក់ទាញវិនិយោគទុនពាណិជ្ជកម្ម។[24]

## ថៃ

ប្រទេសថៃបានទទួលការវិនិយោគទុនពីបរទេស ដែលមានតម្លៃចំនួន១៩កោដិដុល្លារអាមេរិកនៅក្នុងឆ្នាំ២០១៩។[25] កាលពីមួយទសវត្សរ៍មុននេះ ជប៉ុនរួមជាមួយនឹងសហរដ្ឋអាមេរិក អាល្លឺម៉ង់ ចក្រភពអង់គ្លេស និងបារាំង គឺប្រភពវិនិយោគទុនផ្ទាល់ពីបរទេសដែលស្ថិតនៅលំដាប់កំពូលគេជានិច្ចសម្រាប់ប្រទេសថៃ។[26]

នៅក្នុងឆ្នាំ២០១៤ ក្រុមប្រឹក្សាភិបាលនៃការវិនិយោគទុនរបស់ប្រទេសថៃ (BOI) បានប្រកាសចេញនូវផែនការយុទ្ធសាស្ត្រប្រាំពីរឆ្នាំថ្មីមួយ (២០១៥-២០២១) ដើម្បីបន្តទាក់ទាញការវិនិយោគបន្ថែមទៀត រួមបញ្ចូលទាំងការវិនិយោគរបស់ប្រជាជនថៃដែលរស់នៅបរទេស[27]។ យុទ្ធសាស្ត្រដែលចម្បងជាងគេនោះ គឺការផ្ដល់នូវសិទ្ធិពិសេស (បុព្វសិទ្ធិ) ដល់វិនិយោគិនបរទេស ដែលនឹងបោះទុនវិនិយោគលើផ្នែកមួយចំនួន ដូចជាផ្នែកសិក្សាស្រាវជ្រាវនិងការអភិវឌ្ឍ (R&D) ការបង្កើតថ្មី ការបង្កើតគុណតម្លៃក្នុងវិស័យកសិកម្ម ឧស្សាហកម្ម និងសេវាកម្ម លើសហគ្រាសខ្នាតតូចនិងមធ្យម (SMEs) និងលើអ្នកដែលលើកកម្ពស់ការប្រកួតប្រជែងដែលយុត្តិធម៌ស្មើភាពគ្នា និងការរីកចម្រើនសេដ្ឋកិច្ចប្រកបដោយបរិយាប័ន្ន ឬក៏កំណើនសេដ្ឋកិច្ចសម្រាប់មនុស្សទាំងអស់។ វាគឺជាការជឿជាក់មួយរបស់រដ្ឋាភិបាលដែលថាសិទ្ធិពិសេស (បុព្វសិទ្ធិ) ទាំងនេះ នឹងជួយបង្កើនសមត្ថភាពនៃការប្រកួតប្រជែងរបស់ ជាតិនៅក្នុងទីផ្សារថ្នាក់តំបន់និងសកល។[28] នៅក្រោមយុទ្ធសាស្ត្រនេះ ការវិនិយោគផ្ទាល់ពីបរទេសក៏ត្រូវបានណែនាំ ឲ្យទៅបណ្ដាក់ទុននៅក្នុងតំបន់សេដ្ឋកិច្ចពិសេសផងដែរ។ វិស័យដែលត្រូវវិនិយោគនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស មានយានយន្តនិងគ្រឿងបន្លាស់ ឧបករណ៍អគ្គិសនី ឧបករណ៍ទូរគមនាគមន៍ និងអេឡិចត្រូនិចការកែច្នៃកសិកម្ម ភស្តុភា ការផលិតឧបករណ៍វេជ្ជសាស្ត្រ ការផលិតថ្នាំពេទ្យ ដី/តំបន់ឧស្សាហកម្ម វិស័យកាត់ដេរនិងវាយនភ័ណ្ឌ និងវិស័យទេសចរណ៍ដែលពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ វិនិយោគិននឹងត្រូវផ្ដល់ឲ្យនូវរង្វាន់លើកទឹកចិត្តជាពន្ធ លើចំណូលសាជីវកម្មការដកចេញទ្វេដងនៃការចំណាយរបស់វិនិយោគិន ចំពោះការដឹកជញ្ជូនក្នុងអំឡុងពេល១០ ឆ្នាំ ការផ្គត់ផ្គង់ទឹកភ្លើងការលើកលែងចំពោះកាតព្វកិច្ចនាំចូល គ្រឿងម៉ាស៊ីន ការលើកលែងចំពោះកាតព្វកិច្ចនាំចូល វត្ថុធាតុដើម គ្មានការបង់ពន្ធលើការកាន់កាប់ដីធ្លី និងការអនុញ្ញាតឲ្យនាំយកអ្នកជំនាញមកជាមួយ។ មានតំបន់សេដ្ឋកិច្ចពិសេសចំនួន១៣កន្លែង ដែលជាគោលដៅរបស់រដ្ឋាភិបាលក្នុងការទទូចចង់ផ្ដល់ឲ្យនូវរង្វាន់លើកទឹកចិត្តបន្ថែមទៀត។

បញ្ជីវិនិយោគទុនលម្អិតតាមវិស័យ ក្រុមហ៊ុន និងប្រទេសដើមមាននៅក្នុងឧបសម្ព័ន្ធ។

# ទម្រង់បែបបទក្របខ័ណ្ឌការងារថ្នាក់តំបន់ និងសកលលោក

បរិយាកាសវិនិយោគនៅក្នុងតំបន់ទន្លេមេគង្គ ស្របតាមនិងទទួលរងឥទ្ធិពលយ៉ាងខ្លាំងពីស្ថាប័នរូបិយវត្ថុអន្តរជាតិ (IFIs) ដូចជាធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក (WB) សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) និងធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី (AIIB) ហើយនិងពីប្រទេសដែលជាម្ចាស់ជំនួយទ្វេភាគី ដូចជាចិន ជប៉ុន អាល្លឺម៉ង់ សហរដ្ឋអាមេរិកសហភាពអឺរ៉ុប (EU) កូរ៉េខាងត្បូង រុស្ស៊ី ថៃ វៀតណាម និងឥណ្ឌា។ ស្ថាប័នរូបិយវត្ថុអន្តរជាតិ (IFIs) ធនាគារពាណិជ្ជជាតិនិងធនាគារអាហារ៍ណេនីហរ៍ណេជាតិ គឺជាអ្នកផ្ដល់ហិរញ្ញប្បទានដល់គម្រោងថាមពលខ្នាតធំ គម្រោងដឹកជញ្ជូន និង



Many of the resettled villagers were farmers, but they did not receive replacement land when they were resettled, so they lost livelihoods. After 3 years, they are still negotiating to receive an area of common land to use for farming, Thilawa Special Economic Zone, Myanmar. Photo credit: Earth Rights International

គម្រោងហេដ្ឋារចនាសម្ព័ន្ធវិស័យចម្រុះ ខណៈដែលជំនួយទ្វេភាគីតែងតែភ្ជាប់មកជាមួយនូវការគាំទ្រពីសំណាក់ប្រទេសជាម្ចាស់ជំនួយលើការវិនិយោគឯកជន។ នៅក្នុងអំឡុងពេលតែមួយ ប្រទេសនៅតាមដងទន្លេមេគង្គ មានសមាសភាពជាសមាជិករបស់កម្មវិធីវិនិយោគថ្នាក់តំបន់ផង និងថ្នាក់អនុតំបន់ផង ហើយក៏ជាសមាជិកនៃកិច្ចព្រមព្រៀងវិនិយោគពាណិជ្ជកម្មទ្វេភាគី ថ្នាក់តំបន់ និងថ្នាក់សលកលោក។

មួយក្នុងចំណោមកម្មវិធីថ្នាក់តំបន់ដំបូងគេបង្អស់ ដែលបានសម្របសម្រួលលើការធ្វើសមាហរណកម្មសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ចនៅក្នុងតំបន់ទន្លេមេគង្គ គឺកម្មវិធីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចមហាអនុតំបន់ទន្លេមេគង្គ (GMS) ដែលដឹកនាំដោយធនាគារអភិវឌ្ឍន៍អាស៊ី។ បន្ទាប់ពីការផ្តួចផ្តើមឡើងនៅក្នុងឆ្នាំ១៩៩២ មហាអនុតំបន់ទន្លេមេគង្គ បន្តគោលបំណងរបស់ខ្លួនក្នុងការប្រែក្លាយធនធានធម្មជាតិ និងធនធានមនុស្សនៃតំបន់នេះទៅជាតំបន់ពាណិជ្ជកម្មសេរី និងតំបន់វិនិយោគ តាមរយៈការវិនិយោគលើវិស័យចម្រុះពោពេញដោយមហិច្ឆតា ទៅលើវិស័យដឹកជញ្ជូន(ផ្លូវថ្នល់ ផ្លូវដែក ផ្លូវអាកាស និងផ្លូវទឹក) ថាមពល ការពង្រីកទីក្រុង ទូរគមនាគមន៍ ទេសចរណ៍ ការសម្របសម្រួលពាណិជ្ជកម្ម និងកសិកម្ម។ គម្រោងហេដ្ឋារចនាសម្ព័ន្ធមានតម្លៃប្រហែលជាង១១កោដិដុល្លារអាមេរិក ដែលបានចាប់ដំណើរការតាំងពីឆ្នាំ១៩៩២មក គឺបានបញ្ចប់ខ្លះហើយ ឬក៏នៅតែកំពុងអនុវត្តក្រោមគម្រោងមហាអនុតំបន់ទន្លេមេគង្គ។[29] គម្រោងមហាអនុតំបន់ទន្លេមេគង្គត្រូវបានរៀបចំស្ទើរតែទាំងស្រុងដោយបុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ី ទីប្រឹក្សាឯកជន និងក្រុមហ៊ុនឯកជនហើយព្រមទាំងបានផ្តល់នូវជំនួយហិរញ្ញវត្ថុតាមរយៈកម្ចីឥណទាន និងជំនួយដែលមានលក្ខខណ្ឌពីធនាគារអភិវឌ្ឍន៍អាស៊ី និងម្ចាស់ជំនួយទ្វេភាគី។ រដ្ឋាភិបាលសមីត្រូវសងបំណុលទាំងនោះវិញ ដែលអាចចូលរួមថវិកា និងជាការសម្របសម្រួលដល់វិនិយោគទាំងនេះតាមវិធានការគោលនយោបាយផ្សេងៗ និងការទទួលបាននូវដីធ្លី។ ក្នុងន័យមួយ មហាអនុតំបន់ទន្លេមេគង្គមានកម្មវិធីភាពជាដៃគូរវាងសាធារណៈនិងឯកជន «ឈានមុខគេ» នៅទូទាំងតំបន់ ដែលប្រាក់ចំណូលរបស់វិស័យឯកជនត្រូវបានអនុញ្ញាតឲ្យមានចរន្តតាមរយៈហិរញ្ញប្បទានសាធារណៈ។

ចាប់តាំងពីឆ្នាំ១៩៩៨មក ការអភិវឌ្ឍច្រករបៀងសេដ្ឋកិច្ច បានក្លាយទៅជាស្នូលនៃក្របខណ្ឌយុទ្ធសាស្ត្ររបស់មហាអនុតំបន់ទន្លេមេគង្គ។ ច្រករបៀងសេដ្ឋកិច្ចគឺជាតំបន់ ឬតំបន់ដែលនៅដាច់ស្រយាលដែលត្រូវការការអភិវឌ្ឍច្រើន




ប្រភព៖ ធនាគារអភិវឌ្ឍន៍អាស៊ី

លើហេដ្ឋារចនាសម្ព័ន្ធ ដែលមាននិន្នាការក្នុងការទាក់ទាញវិនិយោគឯកជនឲ្យវិនិយោគលើពហុវិស័យ ហេតុដូចនេះហើយរដ្ឋាភិបាល ដាច់ខាតត្រូវតែបង្កើតឲ្យមាននូវគោលនយោបាយ និងបទប្បញ្ញត្តិនានាដែលអនុញ្ញាតឲ្យមានការផលិត និងចែកចាយថាមពល ការធ្វើផលិតកម្មកសិកម្ម ការធ្វើផលិតកម្មផ្សេងៗ ទេសចរណ៍ ការផ្តល់សេវាកម្មឯកជន ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស និងឧទ្យានឧស្សាហកម្ម។ល។ នាពេលបច្ចុប្បន្ន មានច្រករបៀង «សំខាន់ៗ» ចំនួនបី ច្រករបៀងសេដ្ឋកិច្ចខាងកើត និង ខាងលិច (EWEC) លាតសន្ធឹងពីដាណាង ប្រទេសវៀតណាម រហូតដល់ម៉ាវឡាមីយីន៏ (Mawlamyine) ប្រទេសមីយ៉ាន់ម៉ា ច្រករបៀងសេដ្ឋកិច្ចខាងជើងនិងខាងត្បូង (NSEC) លាតសន្ធឹងពីគុនមីង ប្រទេសចិន រហូតដល់បាងកក ប្រទេសថៃ និងច្រករបៀងសេដ្ឋកិច្ចភូមិភាគខាងត្បូង (SEC) ស្ថិតនៅចន្លោះប្រទេសវៀតណាម និងក្រុងបាងកក។ ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ការសម្របសម្រួលពាណិជ្ជកម្ម និងការដឹកជញ្ជូន ការអភិវឌ្ឍព្រំដែន និងច្រកបរៀងក្រុង ការលើកកម្ពស់វិនិយោគ និងការអភិវឌ្ឍសហគ្រាស គឺត្រូវបានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងនៅក្នុងតំបន់ទាំងបីនេះ។ ច្រករបៀងសេដ្ឋកិច្ចទាំងនេះ អាចនឹងត្រូវពង្រីក ឬក៏កែសម្រួលឡើងវិញ ដើម្បីធានានូវការដាក់បញ្ចូលឲ្យបានគ្រប់គ្រាន់នូវប្រទេសមីយ៉ានម៉ា ឡាវ និងផ្លូវពាណិជ្ជកម្មឆ្លងព្រំដែនសំខាន់ៗរវាងប្រទេសចិន និងមីយ៉ាន់ម៉ា មីយ៉ាន់ម៉ានិងថៃ ព្រមទាំងប្រទេសចិននិងឡាវ។ ផ្លូវឆ្លងកាត់ប្រទេសនៅក្នុងតំបន់ «ច្រករបៀងដឹកជញ្ជូន» គឺអាចនឹងត្រូវផ្លាស់ប្តូរទៅជាច្រករបៀងសេដ្ឋកិច្ចយ៉ាងពេញទំហឹង តាមរយៈការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស តំបន់សេដ្ឋកិច្ចឆ្លងដែន និងតំបន់ផលិតកម្មឧស្សាហកម្ម ហើយវាត្រូវបានរំពឹងទុកថានឹងស្រូបទាញបាននូវពលករចំណាកស្រុកពីប្រទេសឡាវ កម្ពុជា និងមីយ៉ាន់ម៉ា និងភ្ជាប់ទំនាក់ទំនងរបស់សហគ្រាសក្នុងស្រុកជាមួយនឹងខ្សែសង្វាក់ផលិតកម្មថ្នាក់តំបន់ និងសកលលោក។[30]

ព័ត៌មានអំពីអាទិភាពនៃការវិនិយោគ និងគម្រោងដែលអាចជាគម្រោងនាពេលអនាគត អាចរកបាននៅក្នុង *ផែនការអនុវត្តន៍ក្របខណ្ឌវិនិយោគមហាអនុតំបន់ទន្លេមេគង្គ (២០១៤-២០១៨)*។[31] មិនចំពោះថាវិស័យណាមួយ ឬក៏ភាសារនានាអំពីការកាត់បន្ថយភាពក្រីក្រ និងការកសាងឲ្យមានភាពបន្សាំចំពោះបម្រែបម្រួលអាកាសធាតុនោះឡើយ ធាតុសំខាន់ៗនៃទស្សនៈវិស័យរបស់មហាអនុតំបន់ទន្លេមេគង្គ គឺធ្វើអ្វីៗគ្រប់យ៉ាងឲ្យក្លាយជាទំនិញសម្រាប់ធ្វើពាណិជ្ជកម្មឯកជនភាវូបនីយកម្ម និងទីផ្សារដែលគ្រប់គ្រងដោយសាជីវកម្មធំៗ។ នៅក្នុងប្រទេសឡាវ កម្ពុជា និងវៀតណាម ច្រករបៀងសេដ្ឋកិច្ចទាំងនេះ គឺអមទៅដោយតំបន់អភិរក្សជីវៈចម្រុះដែលគ្របដណ្តប់លើផ្ទៃដីព្រៃ និងដីដែលមិនមែនជាដីព្រៃចំនួនពីរលានហិចតា ហើយវាត្រូវបានចាត់ទុកថាជាផ្នែក «តំបន់បៃតង» មួយនៃវិធីសាស្រ្តអភិវឌ្ឍន៍ប្រកបដោយចីរភាព។ យុទ្ធសាស្រ្តកសិកម្ម រួមបញ្ចូលទាំងការលើកកម្ពស់កសិពាណិជ្ជកម្ម ការកសាងសមត្ថភាពប្រកួតប្រជែងជាសកល លើសុវត្ថិភាពស្បៀង ការធ្វើទំនើបកម្មលើពាណិជ្ជកម្មកសិកម្ម ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច ប្រព័ន្ធធានារ៉ាប់រងលើអាកាសធាតុបច្ចេកវិជ្ជាជីវៈម៉ាស់ និងការដាក់ស្លាកសញ្ញាថាថៃរក្សាប្រព័ន្ធអេកូឡូហ្ស៊ី ដើម្បីចូលទៅក្នុងទីផ្សារបាន និង មានច្រើនជាងនេះទៀត។ ការសង្កត់ធ្ងន់ដោយផ្តោតយ៉ាងសំខាន់លើ ការធ្វើសមាហរណកម្មកសិករនៅក្នុងតំបន់ ឲ្យចូលទៅក្នុងសង្វាក់ផលិតកម្មថ្នាក់តំបន់/សកល ដែលដឹកនាំដោយសាជីវកម្មកសិពាណិជ្ជកម្ម និងបង្វែរទិសដៅផលិតកម្មកសិកម្មពីការផលិតបានគ្រប់គ្រាន់សម្រាប់ចិញ្ចឹមគ្រួសារ ទៅជាការផលិតសម្រាប់ផ្គត់ផ្គង់ទីផ្សារនៅថ្នាក់តំបន់ និងទីផ្សារសកល។ យុទ្ធសាស្រ្តវិស័យទេសចរណ៍ (TSS) របស់មហាអនុតំបន់ទន្លេមេគង្គ មានគោលបំណងអភិវឌ្ឍ និងលើកកម្ពស់តំបន់ទន្លេមេគង្គឲ្យទៅជាគោលដៅទេសចរណ៍តែមួយគត់ ដែលមាន «ផលិតផលក្នុងអនុតំបន់ប្រកបដោយគុណភាពល្អ និងមានទិន្នផលខ្ពស់ ព្រមទាំងមានភាពសម្បូរបែប»។[32] ការលើកកម្ពស់វិស័យទេសចរណ៍ គឺភ្ជាប់ជាមួយនឹងការគាំទ្រដល់ច្រករបៀងសេដ្ឋកិច្ច និងគម្រោងហេដ្ឋារចនាសម្ព័ន្ធ ដូចជាការសាងសង់អាកាសយានដ្ឋាន និងផ្លូវថ្នល់ឲ្យមានភាពទាន់សម័យនៅក្នុងតំបន់ទេសចរណ៍ អភិវឌ្ឍន៍តំបន់មាត់ទន្លេ ការផ្គត់ផ្គង់ទឹក ភ្លើង ទីផ្សារ និងការធ្វើឲ្យទេសភាពមានភាពស្រស់ត្រកាល។ល។

លើកលែងតែប្រទេសចិនចេញ តំបន់ទន្លេមេគង្គ មានសមាសភាពជាប្រទេសសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន/ASEAN) ដែលគោលដៅចុងក្រោយរបស់ពួកគេចំពោះការធ្វើសមាហរណកម្មសេដ្ឋកិច្ចនោះគឺការបង្កើតនូវសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC)។ សហគមន៍សេដ្ឋកិច្ចអាស៊ាន «មានទស្សនវិស័យថា អាស៊ានមានទីផ្សារតែមួយ និងផ្អែកលើផលិតកម្ម ហើយវាគឺជាតំបន់មួយដែលមានសមត្ថភាពប្រកួតប្រជែងខ្ពស់ ដោយមានការអភិវឌ្ឍសេដ្ឋកិច្ចស្មើៗគ្នា និងមានការធ្វើសមាហរណកម្មពេញលេញទៅក្នុងសេដ្ឋកិច្ចសកល។»[33] ការធ្វើឲ្យសម្រេចបានយ៉ាងពេញលេញនូវសហគមន៍សេដ្ឋកិច្ចអាស៊ាន ត្រូវបានរំពឹងទុកថានឹងអនុញ្ញាតឲ្យមានលំហូរដោយសេរីនូវ ទុន ទំនិញ ពលករ និងជំនាញនៅទូទាំងតំបន់អាស៊ាន ហើយនិងធ្វើឲ្យអាស៊ានក្លាយទៅជាគោលដៅតែមួយគត់សម្រាប់វិនិយោគ។ អាស៊ានបានផ្តួចផ្តើមឲ្យមាននូវកិច្ចព្រមព្រៀងមួយចំនួន ដើម្បីសម្របសម្រួលលើការបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាន ហើយក្នុងចំណោមកិច្ចព្រមព្រៀងទាំងនោះ មានកិច្ចព្រមព្រៀងពាណិជ្ជកម្មអាស៊ានស្តីពីមុខទំនិញ (ATIGA) កិច្ចព្រមព្រៀងលើក្របខណ្ឌអាស៊ានស្តីពីសេវាកម្ម (AFAS) កិច្ចព្រមព្រៀងវិនិយោគទូលំទូលាយរបស់អាស៊ាន

(ACIA) និងកិច្ចព្រមព្រៀងអាស៊ានស្តីពីចលនានៃធម្មជាតិមនុស្សជាតិ (AAMNP)។ កិច្ចព្រមព្រៀងទាំងនេះ ត្រូវបានបង្កើតឡើងដើម្បីជួយដល់វិនិយោគិនឲ្យរក្សាបាននូវការចំណាយទាបចំពោះផលិតកម្ម/មុខជំនួញ និងជួយរក្សាបាននូវចំណូល/ផលប្រយោជន៍ខ្ពស់ ដោយគ្រាន់តែធ្វើឲ្យមានភាពងាយស្រួលសម្រាប់ពួកគេក្នុងការទទួលបានអាជ្ញាប័ណ្ណ ការអនុញ្ញាតទុនវិនិយោគ វត្ថុធាតុដើម ពលករនិងធាតុចូលផ្សេងៗសម្រាប់ផលិតកម្ម និងងាយរកបាននូវទីផ្សារតាមរយៈការវិនិយោគរួមគ្នា និងភាពជាដៃគូរវាងរដ្ឋនិងឯកជន។ ភាពជឿជាក់របស់វិនិយោគិនត្រូវបានបង្កើនឡើង គឺតាមរយៈហេដ្ឋារចនាសម្ព័ន្ធច្បាប់សម្រាប់ការពារសិទ្ធិរបស់វិនិយោគិន និងការវិនិយោគ ការទទួលបាននូវព័ត៌មាន និងឱកាសចូលរួមចំណែកទៅក្នុងការតាក់តែងគោលនយោបាយ។[34]

ប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា វៀតណាម និងថៃគឺជាសមាជិករបស់យុទ្ធសាស្ត្រសហប្រតិបត្តិការសេដ្ឋកិច្ចអាយីយ៉ាវ៉ាឌី ចៅប្រាយ៉ា មេគង្គ (ACMECS) ដែលបានផ្តួចផ្តើមឡើងដោយប្រទេសថៃ និងបានដាក់ឲ្យដំណើរការនៅក្នុងឆ្នាំ២០០៣ ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ជាពិសេសនៅតាមតំបន់ព្រំដែន ដើម្បីប្រែក្លាយតំបន់ទាំងនោះឲ្យក្លាយទៅជា «តំបន់ដែលមានសេដ្ឋកិច្ចរីកចម្រើន។»[35] នៅក្នុងសន្និបាតលើកទីប្រាំពីររបស់យុទ្ធសាស្ត្រសហប្រតិបត្តិការសេដ្ឋកិច្ច អាយីយ៉ាវ៉ាឌី ចៅប្រាយ៉ា មេគង្គ ដែលធ្វើឡើងនៅទីក្រុងហាណូយកាលពីខែតុលា ឆ្នាំ២០១៦ ថ្នាក់ដឹកនាំយុទ្ធសាស្ត្រសហប្រតិបត្តិការនេះ បានបញ្ជាក់ជាថ្មីម្តងទៀតនូវការប្តេជ្ញាចិត្តរបស់ពួកគេ ក្នុងការសម្រេចឲ្យបាននូវកំណើនសេដ្ឋកិច្ច តាមរយៈជីវីស៊ី (GVCs) ការលើកស្ទួយហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនឆ្លងព្រំដែន ការបន្ធូរបន្ថយដល់ការធ្វើពាណិជ្ជកម្មឆ្លងព្រំដែននិងការវិនិយោគ ការបង្កើតតំបន់អភិវឌ្ឍន៍ឧស្សាហកម្មនៅតាមច្រករបៀងសេដ្ឋកិច្ច និងការបង្កើនតួនាទីរបស់វិស័យពាណិជ្ជកម្មនៅក្នុងយុទ្ធសាស្ត្រសហប្រតិបត្តិការសេដ្ឋកិច្ចអាយីយ៉ាវ៉ាឌី ចៅប្រាយ៉ា មេគង្គ។[36]

នៅឆ្នាំ២០១៥ ប្រទេសចិន និងប្រទេសទាំងប្រាំនៅតាមដងទន្លេមេគង្គ បានដាក់ឲ្យដំណើរការនូវកិច្ចសហប្រតិបត្តិការឡានចាងមេគង្គ (LMC) ដែលជាយន្តការសហប្រតិបត្តិការសេដ្ឋកិច្ចអនុតំបន់មួយ ដែលនឹងផ្សារភ្ជាប់ការធ្វើពាណិជ្ជកម្ម និងការវិនិយោគនៅក្នុងតំបន់ទន្លេមេគង្គជាមួយនឹងគំនិតផ្តួចផ្តើម ខ្សែក្រវាត់និងផ្លូវថ្នល់របស់ប្រទេសចិន (Belt and Road Initiative) និងជាមួយនឹងធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី (AIIB)។ នៅក្នុងកិច្ចប្រជុំលើកទីមួយរបស់ពួកគេនាខែមីនា ឆ្នាំ២០១៦ ប្រមុខដឹកនាំកិច្ចសហប្រតិបត្តិការឡានចាងមេគង្គ បានប្តេជ្ញាចិត្តថានឹងជំរុញទៅមុខឲ្យមានការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការដឹកជញ្ជូនតាមផ្លូវទឹក ផ្លូវគោក និងផ្លូវអាកាស ការផលិត និងការបញ្ជូនថាមពល ទូរគមនាគមន៍ តំបន់សេដ្ឋកិច្ចនិងឧស្សាហកម្មនៅតាមព្រំដែន កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចថ្នាក់តំបន់ទូលំទូលាយ (អសឹប/RCEP) និងការសម្របសម្រួលលើវិនិយោគទុនពាណិជ្ជកម្ម។[37]

កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTAs) ជំនាន់ថ្មី (ក៏ហៅបានដែរថា «កិច្ចព្រមព្រៀងនៃភាពជាដៃគូសេដ្ឋកិច្ច») មានវិធានការផ្សេងៗដែលនឹងជួយសម្របសម្រួលដល់ការធ្វើវិនិយោគ រួមបញ្ចូលទាំងការផ្លាស់ប្តូរច្បាប់នៅក្នុងស្រុក។ ប្រទេសនៅតាមដងទន្លេមេគង្គទាំងអស់ គឺជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO) ហើយនិងកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចថ្នាក់តំបន់ទូលំទូលាយ (អសឹប/RCEP) ដែលដឹកនាំដោយប្រទេសចិន។ អាស៊ាន បានធ្វើការចរចាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរួចជាស្រេចមកហើយ ជាមួយនឹងចិន ជប៉ុន កូរ៉េខាងត្បូង ឥណ្ឌា អូស្ត្រាលី និងនូវែលហ្សេឡង់។ ការចរចាលើការដាក់ឲ្យដំណើរការនូវ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី រវាងអាស៊ាន និងសហគមន៍អឺរ៉ុប (EU) ត្រូវបានផ្អាកនៅក្នុងឆ្នាំ២០០៩ ដើម្បីអនុញ្ញាតឲ្យ សហគមន៍អឺរ៉ុបអាចបង្កើតនូវកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីរវាងប្រទេសដែលជាសមាជិកអាស៊ានជាមុនសិន។ បច្ចុប្បន្ននេះ សហគមន៍អឺរ៉ុបមានកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយនឹងប្រទេសវៀតណាមហើយ ហើយកំពុងតែចរចាជាមួយនឹងប្រទេសមីយ៉ាន់ម៉ា ឲ្យមានកិច្ចព្រមព្រៀងលើការការពារវិនិយោគិន។[38]

ថ្មីៗនេះ ប្រទេសវៀតណាមបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងភាពជាដៃគូអន្តរទ្វីបប៉ាស៊ីហ្វិច (TPP) ហើយប្រទេសថៃកំពុងតែស្វែងរកឱកាសចូលរួមដែរ។ មកដល់ពេលនេះ កិច្ចព្រមព្រៀងវិនិយោគទុនអន្តរជាតិ (IIAs)[39] ចំនួន៣៩៨ ត្រូវបានចុះហត្ថលេខាដោយរដ្ឋាភិបាលនៅក្នុងតំបន់នេះ។ គ្រាន់តែប្រទេសចិនមួយ បានចុះហត្ថលេខាលើកិច្ច ព្រមព្រៀងវិនិយោគទុនអន្តរជាតិ (IIAs) ចំនួន១៤៩ឯណោះ បន្ទាប់មកគឺប្រទេសវៀតណាមបានចុះហត្ថលេខាលើ កិច្ចព្រមព្រៀងវិនិយោគទុនអន្តរជាតិចំនួន៨៣ ថៃចំនួន៦២ ឡាវចំនួន៤០ កម្ពុជាចំនួន៣៩ និងមីយ៉ាន់ម៉ាចំនួន២៥។[40]

# តំបន់សេដ្ឋកិច្ចពិសេស (SEZs)

*ការពង្រីកទីតាំងតំបន់សេដ្ឋកិច្ចពិសេសពីចំនួនប្រហែល៥០០កន្លែងនៅក្នុងឆ្នាំ១៩៩៥ រហូតដល់ជាង៤៣០០កន្លែងនៅក្នុងឆ្នាំ២០១៥នោះ បានបង្ហាញពីការកើនឡើងយ៉ាងមុតមាំនូវចំណាប់អារម្មណ៍ ចំពោះទម្រង់ពិសោធន៍គោលនយោបាយបែបនេះ ទោះបីជាកំណត់ត្រាពីភាពជោគជ័យនៅមិនទាន់ ច្បាស់លាស់នៅឡើយក្តី...ប្រសិនបើរៀបចំបានត្រឹមត្រូវនោះ តំបន់សេដ្ឋកិច្ចពិសេសអាចក្លាយជាយាន សម្រាប់បង្កើនការធ្វើពាណិជ្ជកម្ម ការវិនិយោគផ្ទាល់ពីបរទេស និងការបង្កើត និងកែទម្រង់គោលនយោបាយ សេដ្ឋកិច្ចឲ្យបានល្អ ប្រសើរជាងមុន។ នៅពេលដែលប្រទេសបានអភិវឌ្ឍហើយនោះ កន្លែងដែលមានតំបន់សេដ្ឋកិច្ចពិសេស អាចត្រូវបានផ្លាស់ប្តូរពីទីតាំងធ្វើផលិតកម្មទៅជាសម្រាប់ការបង្កើតថ្មីនិងសេវាទំនើបៗ។*

ហ្សាងជីន វ៉ៃយ៍ (Shang-Jin Wei) នាយកផ្នែកសេដ្ឋកិច្ចនៃធនាគារអភិវឌ្ឍន៍អាស៊ី[41]

តំបន់សេដ្ឋកិច្ចពិសេស គឺជាតំបន់មួយដែលបានកំណត់ និងបង្កើតឡើងដើម្បីបង្កើនសមត្ថភាពប្រកួតប្រជែងលើវិស័យឧស្សាហកម្ម ទាក់ទាញវិនិយោគផ្ទាល់ពីបរទេស បង្កើតនិងជម្រុញការនាំចេញចំរុះ បង្កើតការងារ និងសាកល្បងអនុវត្តគោលនយោបាយនិងវិធីសាស្ត្រថ្មីៗ។ តំបន់នេះត្រូវបានបង្កើតឡើងដោយមាននូវបុព្វសិទ្ធិផ្សេងៗសម្រាប់វិនិយោគិនដែលរួមបញ្ចូលទាំងការលើកលែងពន្ធលើការនាំចូលវត្ថុធាតុដើម និងការលើកលែងពន្ធលើចំណូលសាជីវកម្ម ការលើកទឹកចិត្ត ផ្នែកពន្ធអាករមានធាតុចូលផ្សេងៗ ដូចជាអគាររោងចក្រ និងមានឃ្លាំងសម្រាប់ផលិតកម្ម មានបរិក្ខារសម្រាប់ប្រតិបត្តិការ និងមានសេវាសំខាន់ៗដូចជា មធ្យោបាយដឹកជញ្ជូន ទឹកនិងភ្លើង ជាតំបន់យុទ្ធសាស្ត្រដែលងាយស្រួលនឹងទៅដល់កំពង់ផែសមុទ្ទ និងជាចំណុចកណ្តាលនៃការដឹកជញ្ជូន និងឆ្លងកាត់ ឬក៏មានភាពទន់ខ្សោយចំពោះការការពារបរិស្ថាននិងពលករជាតិ។ តំបន់សេដ្ឋកិច្ចពិសេស គឺជាតំបន់ដែលមានកំពង់ផែសេរី តំបន់ពាណិជ្ជកម្មសេរី តំបន់កែច្នៃការនាំចេញ តំបន់ឧស្សាហកម្មសេរី និងជាតំបន់សហគ្រាស។ តំបន់សេដ្ឋកិច្ចពិសេស ត្រូវបានចាត់ទុកថាជាកន្លែងចាប់ផ្តើមធ្វើពាណិជ្ជកម្មដ៏ល្អមួយ សម្រាប់វិនិយោគិនបរទេស ពីព្រោះជាកន្លែងដែលងាយស្រួល ក្នុងការអនុវត្តគម្រោង ដោយសារតែវិនិយោគិន/អ្នកជំនួញ ពុំចាំបាច់ចូលរួមក្នុងការឈូសឆាយសម្អាតទីតាំង និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធនោះទេ ហើយមិនចាំបាច់មានកាតព្វកិច្ចអ្វីទាំងអស់ នៅពេលដែលនាំចូលវត្ថុធាតុដើម និងនាំចេញនូវផលិតផលសម្រេច។ អ្នកទទួលខុសត្រូវឃ្លាំងគយនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស អាចផ្តល់នូវសេវាដឹកជញ្ជូន និងដើរតួនាទីជាអ្នកចែកចាយទំនិញដែលបានកក់ទុកមុន ទោះបីជាមានសេវាបន្ថែមពាក់ព័ន្ធនឹងការប្រកាសប្រាប់គយពីទំនិញនាំចូល ការវាយតម្លៃ ការធានារ៉ាប់រង ការកែច្នៃឡើងវិញ ឬការវេចខ្ចប់ ដែលទាមទារឲ្យមានការអនុញ្ញាតពីការិយាល័យគយដែលត្រូវទទួលបន្ទុកក្តី។ តំបន់សេដ្ឋកិច្ចពិសេសភាគច្រើនមាន «សេវាច្រកចេញចូលតែមួយ» ដែលជួយពន្លឿញនីតិវិធីវិនិយោគ និងសម្រួលដល់លំហូរពាណិជ្ជកម្ម។

នៅក្នុងតំបន់សេដ្ឋកិច្ចពិសេសភាពជាម្ចាស់កម្មសិទ្ធិក្រុមហ៊ុនអាចជារបស់រដ្ឋឬក៏ឯកជនសុទ្ធសាធ ឬភាពជាម្ចាស់កម្មសិទ្ធិអាចជាការចែកភាគហ៊ុនគ្នារវាងរដ្ឋនិងដៃគូដែលមកពីវិស័យឯកជន។ តំបន់សេដ្ឋកិច្ចពិសេសត្រូវបានធ្វើសមាហរណកម្មចូលទៅក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិរបស់ប្រទេសនៅតាមដងទន្លេមេគង្គ ដើម្បីសម្រេចឲ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់នឹងឆាប់រហ័ស។ តំបន់សេដ្ឋកិច្ចពិសេស ត្រូវបានមើលឃើញថាជាឧបករណ៍សំខាន់មួយ ក្នុងការទាក់ទាញវិនិយោគផ្ទាល់ពីបរទេស និងជាឱកាសសម្រាប់ពង្រីកការវិនិយោគឆ្លងប្រទេស។ ចំពោះវិនិយោគិនឯកជន តំបន់សេដ្ឋកិច្ចពិសេសគឺជាឱកាសមួយសម្រាប់ឈានចូលទៅក្នុងទីផ្សារថ្នាក់តំបន់និងសកល ដោយទទួលបាននូវប្រយោជន៍ពីដីថ្លៃសេវាកម្មផ្សេងៗ និងតម្លៃពលកម្មថោកដែលបានផ្តល់ឲ្យដោយប្រទេសជាម្ចាស់ផ្ទះ។ មានតំបន់សេដ្ឋកិច្ចពិសេសជាង៥០០កន្លែងនៅក្នុងតំបន់ទន្លេមេគង្គទាំងមូល ហើយវាស្ថិតនៅក្នុងដំណាក់កាលអនុវត្តផ្សេងៗគ្នានៅតាម ប្រទេសនីមួយៗ។[42] នៅប្រទេសមីយ៉ាន់ម៉ា គម្រោងតំបន់សេដ្ឋកិច្ចពិសេសធំៗជាងគេទាំងបីមាន ចៅភ្យូ (Kyauk Phyu) ធីឡាវ៉ា (Thilawa) និងដាវ៉ៃយ៍ (Dawei) ហើយតំបន់ទាំងនោះស្ថិតនៅក្នុងដំណាក់កាលកំពុងអភិវឌ្ឍន៍ រីឯនៅ កម្ពុជាមានតំបន់សេដ្ឋកិច្ចពិសេសចំនួន១៩កន្លែង និងនៅវៀតណាមមានប្រមាណជាង៤០០កន្លែង ចំណែកឯឡាវ មាន១០កន្លែង ហើយនៅយុនណានមានមួយកន្លែងដែលកំពុងតែមានប្រតិបត្តិការ។

រដ្ឋាភិបាលនិងអ្នកគាំទ្រតំបន់សេដ្ឋកិច្ចពិសេសបានលើកឡើងថា តំបន់សេដ្ឋកិច្ចពិសេសបង្កើតឲ្យមានការងារធ្វើ បង្កើនឱកាសការងារ ធ្វើអោយមានការអភិវឌ្ឍតាមបែបវិមជ្ឈការ នាំយកនូវទំនើបកម្មទៅបណ្តាលខេត្តនៅជនបទ និងតភ្ជាប់គម្លាតរវាងទីក្រុងនិងតំបន់ជនបទ។ ប៉ុន្តែ បើយោងតាមសហជីពកម្មករ និងអង្គការសិទ្ធិការងារវិញ ការបង្កើតការងារតែមួយមុខគឺមិនគ្រប់គ្រាន់នោះទេ។ ពោលគឺត្រូវតែធានាថាមានការគោរព និងការការពារសិទ្ធិកម្មករ ហើយកម្មករមានការងារសមរម្យ និងទទួលបានប្រាក់ឈ្នួលដែលអាចអោយរស់នៅបាន។ នៅក្នុងកិច្ចសម្ភាសមួយជាមួយនឹងហ្វ័រយើសនាខែកក្កដា ឆ្នាំ២០១៦កន្លងទៅនេះ ថ្នាក់ដឹកនាំសហជីពម្នាក់ (ដែលបានសុំមិនបញ្ចេញឈ្មោះដើម្បីសុវត្ថិភាព) នៅក្នុងតំបន់សេដ្ឋកិច្ចពិសេសខេត្តព្រះសីហនុ (SSEZ) នៃប្រទេសកម្ពុជា បាននិយាយអំពីលក្ខខណ្ឌការងារមិនល្អ និងការបំភិតបំភ័យបំបាក់ស្មារតី និងការដាក់ទណ្ឌកម្មលើកម្មករប្រសិនបើពួកគេព្យាយាមចូលជាសមាជិកសហជីពណាមួយ ការបង្ខំឲ្យធ្វើការថែមម៉ោង និងគំរាមបណ្តេញចេញពីការងារ ឬមិនបន្តកិច្ចសន្យាការងារ ហើយនិងការទទួលបានប្រាក់ឈ្នួលទាប។ ការបង្កើតសហជីពត្រូវបានហាមឃាត់យ៉ាងតឹងរ៉ឹង ជាពិសេសប្រសិនបើកម្មករ ចង់បង្កើតនូវសហជីពមូលដ្ឋាន ដែលមានភ្ជាប់ទំនាក់ទំនងជាមួយនឹងសហជីពឯករាជ្យណាមួយ។ ការប្រព្រឹត្តបែបជិះជាន់មកលើកម្មករ គឺស្តែងចេញនៅក្នុងរូបភាពដូចជា ការផ្លាស់ប្តូរផ្នែកការងារនៅក្នុងខ្សែសង្វាក់ផលិតកម្ម ការកាត់ប្រាក់ខែ ការហាមមិនឲ្យថែមម៉ោង បើទោះជានៅពេលដែលកម្មករត្រូវការក៏ដោយ ការរំលោភបំពានជាពាក្យសំដី ទៅលើកម្មករ និងការមិនបន្តកិច្ចសន្យាការងារជាដើម។ ប្រាក់ខែគោលនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសខេត្តព្រះសីហនុ ជាទូទៅមានចំនួនទាប។ មានរោងចក្រមួយចំនួន បានបង់ប្រាក់ឈ្នួលទៅតាមអ្វីដែលបានកំណត់នៅក្នុងច្បាប់ការងារ ហើយមានរោងចក្រមួយចំនួនទៀតមិនបានគោរពតាមច្បាប់នោះទេ។

កាលពីខែកក្កដា ឆ្នាំ២០១៦ដដែលនេះ ហ្វ័រយើសក៏បានសម្ភាសជាមួយនឹងថ្នាក់ដឹកនាំសហជីពឯករាជ្យម្នាក់និងបុរសជាកម្មករម្នាក់នៅក្នុងតំបន់សេដ្ឋកិច្ចពិសេសផ្សេងមួយទៀតនៅកម្ពុជា គឺតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ (PPSEZ) ហើយអ្នកទាំងពីរបានស្នើសុំមិនបញ្ចេញអត្តសញ្ញាណនោះទេ។ ពួកគេបានរាយការណ៍ថាការបង្កើតសហជីពគឺត្រូវបានរិតត្បិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ជាពិសេសជាមួយនឹងសហជីពដែលចូលរួមធ្វើកូដកម្មទាមទារដំឡើងប្រាក់ខែគោលកាលពីឆ្នាំ២០១៤។ ប្រសិនបើក្រុមហ៊ុនដឹងថាកម្មករកំពុងតែព្យាយាមបង្កើតសហជីពមួយនៅក្នុងក្រុមហ៊ុន របស់ពួកគេ



A rubber plantation in Savannakhet, Lao PDR, by a Vietnamese company.

កម្មករទាំងនោះនឹងត្រូវទទួលទណ្ឌកម្ម ហើយក្នុងករណីដែលអាក្រក់បំផុតនោះគឺត្រូវបញ្ឈប់ពីការងារ។ នៅពេលដែលកម្មករត្រូវបានបញ្ឈប់ពីការងាររបស់ក្រុមហ៊ុនមួយហើយ ពួកគេមិនអាចរកការងារផ្សេងទៀតបានទេនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសដដែលនោះ ពីព្រោះឈ្មោះរបស់ពួកគេត្រូវបានកត់ត្រា ទុកហើយចែកចាយទៅដល់ក្រុមហ៊ុនផ្សេងៗទៀតដែលស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសដដែលនោះ។

ដោយសារបញ្ហាហិរញ្ញវត្ថុ ចាប់តាំងពីឆ្នាំ២០១២មានដំណើរការវិវឌ្ឍន៍ទៅមុខតិចតួចណាស់ ចំពោះកិច្ចប្រតិបត្តិការនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសដាវ៉ៃយ៍ (DSEZ)។ ប៉ុន្តែរបាយការណ៍ មកពីស្ថាប័នពាក់ព័ន្ធមួយចំនួនផ្សេងៗគ្នា រួមបញ្ចូលទាំងសហជីពស្ត្រីតាវុយ៉ាន (TWU) សមាគមអភិវឌ្ឍន៍ដាវ៉ៃយ៍ (DDA) បណ្តាញជនជាតិដើមភាគតិច និងទន្លេតេណាស្សារីម (TRIP NET) សមាគមស្រាវជ្រាវលើការអភិវឌ្ឍដាវ៉ៃយ៍ (DRA) និងអង្គការសង្គមស៊ីវិលដទៃទៀត ដែលធ្វើការយ៉ាងកៀកកិតទៅលើបញ្ហានេះ បានបង្ហាញថាដំណើរការអភិវឌ្ឍន៍គម្រោងតំបន់សេដ្ឋកិច្ច ពិសេសដាវ៉ៃយ៍ (DSEZ) បានផ្តល់ផលប៉ះពាល់អវិជ្ជមាន មកលើសហគមន៍ជាច្រើនរួចមកហើយ។ សហគមន៍ដែលរងផលប៉ះពាល់ បានបាត់បង់ជីវភាពរស់នៅរបស់ពួកគេ ដោយសារតែការរឹបអូសដីធ្លី ការបំផ្លាញដីស្រែចម្ការនិងការរឹតត្បិតមិនឲ្យនេសាទនៅតាមតំបន់ឆ្នេរសមុទ្រ។ អ្នកភូមិខ្លះ ទទួលបាននូវសំណងចំពោះការបាត់បង់របស់ពួកគេ ប៉ុន្តែអ្នកខ្លះទៀតពុំទាន់ទទួលបានអ្វីទាំងអស់។ ផលប៉ះពាល់សំខាន់ៗ រួមមានអសន្តិសុខស្បៀង ឪពុកម្តាយគ្មានលទ្ធភាពបញ្ជូនកូនទៅរៀន និងការរំលោភបំពានផ្លូវភេទលើស្ត្រីពីសំណាក់អ្នកចំណូលថ្មីនៅក្នុងសហគមន៍មូលដ្ឋាន បណ្តាលមកពីការអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសដាវ៉ៃយ៍ (DSEZ)។

នៅក្នុងឆ្នាំ២០១៤ មានរបាយការណ៍ពីរដែលមានចំណងជើងថា *ជីវិតរបស់យើងមិនមែនសម្រាប់លក់ទេ* សរសេរដោយសហជីពស្ត្រីតាវុយ៉ាន (TWU) និង *សម្លេងពីមូលដ្ឋាន៖ ក្តីកង្វល់ចំពោះតំបន់សេដ្ឋកិច្ចពិសេសដាវ៉ៃយ៍ និងគម្រោងពាក់ព័ន្ធនានា* សរសេរដោយក្រុមសង្គមស៊ីវិល និងក្រុមចលនាសង្គមមួយក្រុម ត្រូវបានបោះពុម្ពផ្សាយ ដើម្បីលើកឡើងពីការក្តីបារម្ភចំពោះការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសដាវ៉ៃយ៍ (DSEZ)។ របាយការណ៍ទាំងពីរនេះ បានបង្ហាញនូវព័ត៌មានអំពីទំហំនៃគម្រោង អ្នកបង្កើតតំបន់សេដ្ឋកិច្ចពិសេស ក្តីរំពឹងទុកទៅលើកម្លាំងពលកម្មដែលត្រូវជួល និងចំនួនឧស្សាហកម្មសម្រាប់វិនិយោគ ព្រមទាំងផលប៉ះពាល់អវិជ្ជមានដោយផ្ទាល់ពីគម្រោងនេះទៅដល់ប្រជាជនមូលដ្ឋាន បញ្ហាសំណង និងសេរីភាពរបស់គម្រោង ដែលជាដំណើរការនៃការព្រមព្រៀងគ្នាជាមុន និងជាព័ត៌មាន (FPIC)។ របាយការណ៍ទាំងនេះក៏បានបង្ហាញនូវសំណើមួយចំនួនរបស់សហគមន៍មូលដ្ឋាន និងក្រុមសង្គមស៊ីវិលទៅរដ្ឋាភិបាលភូមានិងថៃ និងទៅអ្នកបង្កើតគម្រោង។ សំណើទាំងនេះផ្តោតជាចម្បងទៅលើ ការទាមទារអោយផ្អាកគម្រោងនេះជាបន្ទាន់ ប្រគល់ដីដែលបានរឹបអូសទៅម្ចាស់ដើមវិញ បញ្ឈប់ការរឹតត្បិតប្រជាជនមូលដ្ឋានមិនឲ្យទៅអាស្រ័យផលនៅតាមតំបន់ឆ្នេរ បើកឲ្យសាធារណជនប្រើប្រាស់ដោយសេរីលើផ្លូវថ្នល់ទាំងឡាយដែលបានសាងសង់សម្រាប់គម្រោង និងផ្ទេរសំណង់អគារនៅក្នុងតំបន់ប្រតិបត្តិការនៃគម្រោងទៅឲ្យសហគមន៍មូលដ្ឋានប្រើប្រាស់សម្រាប់ជាប្រយោជន៍សាធារណៈ។

មានរបាយការណ៍ស្រាវជ្រាវពីរផ្សេងទៀតដែលមានចំណងជើងថា*យើងធ្លាប់តែភ័យខ្លាចគ្រាប់កាំភ្លើង ឥឡូវនេះយើងភ័យខ្លាចនឹងម៉ាស៊ីនឈូសឆាយដី (អាប៊ិល)៖ អាជីវកម្មរុករករ៉ែត្បូងថ្មដ៏កខ្វក់របស់បក្សពួកដៃជើងក្រុមយោធា និងក្រុមហ៊ុនថៃ នៅបានឆូង (Ban Chaung) ស្រុកដាវ៉ៃយ៍ ប្រទេសមីយ៉ាន់ម៉ា* ដែលបានចេញផ្សាយនៅខែតុលា ឆ្នាំ២០១៥ និង ការស្រាវជ្រាវមួយទៀតស្តីពី *ការវិនិយោគឆ្លងប្រទេសនិងទំនួលខុសត្រូវលើយុត្តិធម៌សង្គមនិងបរិស្ថាន៖ មេរៀនពីគោលនយោបាយអភិវឌ្ឍឧស្សាហកម្ម និងការអនុវត្តពីប្រទេសជប៉ុននិងថៃ* ដែលបានចេញផ្សាយនាដើមឆ្នាំ២០១៦។ របាយការណ៍ទីមួយ បានបង្ហាញពីរបៀបដែលគម្រោងតំបន់សេដ្ឋកិច្ចពិសេសដាវ៉ៃយ៍ (DSEZ) ត្រូវបានជំរុញឲ្យមានទោះបីជាមានការប្រឆាំងដាច់ខាត ពីសហគមន៍មូលដ្ឋានយ៉ាងណាក៏ដោយ។ របាយការណ៍នោះ បានចងក្រងពីផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដែលបានកើតឡើងរួចមកហើយទៅលើសុខភាព ជីវភាព សន្តិសុខ និងរបៀបរស់នៅរបស់ប្រជាជនព្រមទាំងការបំពុលបំផ្លាញទន្លេ និងបឹងបួនៅមូលដ្ឋាន។ របាយការណ៍នេះ ក៏បានអំពាវនាវឲ្យផ្អាកប្រតិបត្តិការរុករករ៉ែនៅ ក្នុងតំបន់របស់សហគមន៍ផងដែរ។ របាយការណ៍ទីពីរ បានពិនិត្យលើបរាជ័យនៃគម្រោងឧស្សាហកម្មខ្នាតធំចំនួនបីដែល បានកសាងឡើងនៅក្នុងប្រទេសជប៉ុន និងថៃកាលពីច្រើនទសវត្សរ៍កន្លងទៅនេះ ដែលជាលទ្ធផលវាបានបំផ្លាញជីវិតរបស់សហគមន៍មូលដ្ឋាន និងបរិស្ថានរបស់ពួកគេ។[43]

ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសដាវ៉ៃយ៍ (DSEZ) ត្រូវបានរំពឹងទុកថានឹងនាំមកនូវការផ្លាស់ប្តូរ និងទំនើបកម្មដល់តំបន់តានីថារីយី (Tanitharyi) ទាំងមូល។ ទោះបីជាយ៉ាងនេះក្តី សាវ ហ្វ្រែងគី (Saw Frankie) នាយកប្រតិបត្តិនៃបណ្តាញជនជាតិដើមភាគតិចនិងទន្លេតេណាស្សារីម (Trip Net) ដែលជាអង្គការមួយធ្វើការងារគាំទ្រដល់ការតស៊ូ និងការការពារអត្តសញ្ញាណរបស់សហគមន៍ការ៉ែន (Karen) នៅភូមិកាម៉ូតវ៉េយ៍ (Kamoethway) ដែលជាភូមិមួយមានទីតាំងស្ថិត

នៅប្រហែលជា១០គីឡូម៉ែត្រ ពីតំបន់សេដ្ឋកិច្ចពិសេសដាវេយ៍ (DSEZ) បានបង្ហាញពីក្តីបារម្ភរបស់គាត់ចំពោះ គម្រោងដែលនឹងនាំមកនូវផលប៉ះពាល់អវិជ្ជមាន ជាជាងនាំមកនូវផលប្រយោជន៍ដល់ប្រជាជននៅមូលដ្ឋាន។

*«ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសដាវ៉េយ៍ (DSEZ) នឹងបង្កភាពងាយស្រួលដល់អ្នកមកពីខាងក្រៅតំបន់នូវលទ្ធភាពទទួលបានធនធានផ្សេងៗដែលមានស្រាប់ពីក្នុងតំបន់ដាវ៉េយ៍ទាំងមូល។ នេះរាប់បញ្ចូលទាំងក្រុមហ៊ុនកសិពាណិជ្ជកម្មដែលនឹងអាចប្តូរការធ្វើកសិកម្មតាមបែបប្រពៃណីរបស់សហគមន៍មូលដ្ឋានដែលបានអនុវត្តជាយូរយារណាស់មកហើយ ឲ្យទៅជាការដាំដុះដំណាំអាជីវកម្ម ដូចជាពោត ដំឡូងមី និងកៅស៊ូជាដើម ដែលសហគមន៍នឹងបាត់បង់ទាំងស្រុងនូវជីវភាពរស់នៅនិងអត្តសញ្ញាណរបស់ពួកគេនាពេលអនាគត។»*

# ផលប្រយោជន៍របស់វិនិយោគនមុនសិទ្ធិប្រជាជននិងធម្មជាតិ

ការវិនិយោគខ្នាតធំក្នុងស្រុក និងមកពីបរទេសនៅក្នុងតំបន់ទន្លេមេគង្គ ត្រូវបានប្រើប្រាស់ជាហេតុផលសំខាន់មួយពីសំណាក់រដ្ឋាភិបាលម្ចាស់ផ្ទះ ស្ថាប័នគោលនយោបាយអន្តរជាតិ ស្ថាប័នរូបិយប័ណ្ណអន្តរជាតិ (IFIs) និងអ្នកផ្តល់ហិរញ្ញប្បទានដទៃទៀត (financiers) ក្នុងការសម្រេចបាននូវកំណើតសេដ្ឋកិច្ចបង្កើនសមត្ថភាពប្រកួតប្រជែងខាងផ្នែកសេដ្ឋកិច្ច ធ្វើទំនើបកម្មលើវិស័យកសិកម្ម ប្រើប្រាស់ដីធ្លីនិងធនធានដែល «មិនបានប្រើប្រាស់» ឬ «ទុកចោល» ឲ្យមានផលចំណេញជាងនេះនិងបង្កើត/បង្កើនការងារ។ ប៉ុន្តែការវិនិយោគទាំងនេះ ក៏ពាក់ព័ន្ធការកេងប្រវ័ញ្ចធនធានធម្មជាតិ (ជាពិសេសធនធានដី និងទឹក) និងកម្លាំងពលកម្មផងដែរ។ ជាទូទៅ ការថយចុះនៃការវិនិយោគសាធារណៈ និងការការពារសង្គមនិងបរិស្ថាន ស្របជាមួយនឹងការកើនឡើងនូវឯកជនភាវូបនីយកម្ម ព្រមទាំងកម្មវិធី ភាពជាដៃគូរវាងសាធារណៈ និងឯកជន (PPPs) នៅទូទាំងតំបន់ ចង្អុលបង្ហាញថាតួនាទីសាធារណៈរបស់រដ្ឋ កាន់តែមានការតិចទៅៗ។ ដើម្បីសម្រេចបាននូវកំណើនសេដ្ឋកិច្ច រដ្ឋាភិបាលបានដកថយពីតួនាទីរបស់ពួកគេ ក្នុងការធានាឲ្យមានសុខុមាលភាព និងសិទ្ធិមូលដ្ឋានដល់ប្រជាពលរដ្ឋរបស់ពួកគេ ស្របពេលដែលផលប្រយោជន៍សាធារណៈ ត្រូវបានបកស្រាយទៅជាការចូលរួមពីវិស័យឯកជន និងវិនិយោគខ្នាតធំ។ ខណៈដែលធនធានមានការកើនឡើងនៅក្នុងរាជធានី និងក្នុងទីក្រុងធំៗមួយចំនួន តំបន់ជនបទនៅតែស្ថិតក្នុងភាពក្រីក្រ ជាមួយលទ្ធភាពទទួលសេវាមូលដ្ឋាននូវមានកម្រិតទាបនៅឡើយ។

គ្រប់ប្រទេសទាំងអស់នៅក្នុងតំបន់ទន្លេមេគង្គ មាននាយកដ្ឋានពិសេសរបស់រដ្ឋាភិបាល ដែលដាក់ថាមពលក្នុងការបញ្ចុះបញ្ចូល និងចរចាលើកិច្ចសន្យាជាមួយវិនិយោគិនទាំងឯកជន និងរដ្ឋខ្នាតធំម្ចាស់ជំនួយនិងម្ចាស់ឥណទានជាដើម។ ប៉ុន្តែមានការទទួលស្គាល់ និងដឹងជាផ្លូវការតិចតួចណាស់ពីសំណាក់កសិករ អ្នកនេសាទតាមបែបបុរាណ ប្រជាជនដែលជនជាតិដើមភាគតិច សហគ្រាសខ្នាតតូចក្នុងស្រុក និងកម្មករ អំពីវិនិយោគ ការផ្លាស់ប្តូរនូវជីវិត ជីវភាពរស់នៅ ប្រាក់ចំណូល និងបរិស្ថានរបស់ពួកគេ ដែលបណ្តាលមកពីលំហូរចូលនៃវិនិយោគទុនខ្នាតធំ ដែលកំពុងតែហូរចាក់ចូលទៅក្នុងតំបន់នេះ។ ប្រជាជនមូលដ្ឋាន បានដាក់ទុនវិនិយោគគួរឲ្យកត់សម្គាល់ និងយ៉ាងមានតម្លៃ ទៅក្នុងស្រែ ការនេសាទការសាកវប្បកម្ម ប្រព្រព័ន្ធអេកូឡូហ្ស៊ី និងសហគមន៍របស់ពួកគេ។ ពួកគេការពារព្រៃឈើ ទន្លេ បឹងបួ ដីវាលទំនាប ដីសម្បហភាព និងដីជីវៈចម្រុះ។ ស្បៀងអាហារភាគច្រើននៅក្នុងតំបន់ និងក្នុងឧស្សាហកម្មទំនិញ គឺពួកគេជាអ្នកផលិត ហើយពួកគេគឺជាមូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ចក្នុងស្រុក។ ប៉ុន្តែការវិនិយោគរបស់ពួកគេ និងសិទ្ធិរបស់ពួកគេក្នុងនាមជាវិនិយោគិន គឺពុំទទួលបាននូវការការពារ ដូចប្រយោជន៍របស់ពួកវិនិយោគិនខ្នាតធំឡើយ។ គោលនយោបាយនិងច្បាប់ដែលសម្រួលដល់ការវិនិយោគ បានធ្វើឲ្យធ្លាក់ចុះនូវស្តង់ដារ (បទដ្ឋាន) និងកម្រិតនៃការការពារការងារ ព្រមទាំងបរាជ័យក្នុងការធ្វើឲ្យលក្ខខណ្ឌការងារ ប្រាក់ឈ្នួល និងផលប្រយោជន៍របស់កម្មករមានភាពល្អប្រសើរឡើង។

ការទទួលបានដីធ្លី គឺជាលក្ខខណ្ឌចាំបាច់ខានមិនបាន ដែលត្រូវតែទទួលបានសម្រាប់គម្រោងលើវិស័យកសិកម្ម ឧស្សាហកម្ម ថាមពលដឹកជញ្ជូន ទេសចរណ៍ និងការអភិវឌ្ឍដីធ្លី/អចលនទ្រព្យ ទាំងនៅក្នុងទីក្រុងនិងនៅតំបន់ជនបទ។ គម្រោងវារីអគ្គីសនីនៅតាមដងទន្លេមេគង្គ និងទន្លេផ្សេងៗទៀតនៅក្នុងអាងស្តុកទឹកធម្មជាតិ (ដូចជាទន្លសាលវីន (Salween) ទន្លេណាមធឿន (Nam Theun) ទន្លេមុន (Mun) ទន្លេសេកុង និងទន្លេសេសាន) បានធ្វើឲ្យកម្រិតកម្ពស់ទឹក និងលំហូរទឹកមានការប្រែប្រួល ហើយជាលទ្ធផលវាបានទៅជន់លិចព្រៃ ស្រែ និងឆ្នេរទន្លេ។ ដីធ្លីត្រូវបានរឹបអូសយកពីកសិករ អ្នកនេសាទ និងជនជាតិដើមភាគតិច ហើយសូម្បីតែសហគមន៍មូលដ្ឋានក្តី គឺតែងតែរង

ការបង្ខិតបង្ខំឲ្យចាកចេញពីទីកន្លែងរបស់ពួកគេ ដើម្បីបើកផ្លូវឲ្យមានការសាងសង់ទំនប់ ប្រឡាយ ស្ពានីយថាមពល។ល។ ការជួលដីរយៈពេលវែងឲ្យទៅវិនិយោគិន ទោះបីជាសម្រាប់ធ្វើចម្ការដំណាំ កន្លែងទេសចរណ៍ អចលនទ្រព្យ ឬតំបន់សេដ្ឋកិច្ចពិសេសក្តី វាបានបង្កឲ្យមានបញ្ហាគ្មានដីធ្លី គ្មានការងារធ្វើ និងអសន្តិសុខស្បៀង។ ធនធានដីកសិកម្ម និងធនធានទឹកត្រូវបានបំពុលយ៉ាងគ្រោះថ្នាក់បំផុត ដោយសារតែការប្រើប្រាស់សារធាតុគីមីដែលមានគ្រោះថ្នាក់ខ្លាំងបំផុតហួសកម្រិត។ នៅក្នុងសង្គមដែលពឹងផ្អែកលើវិស័យសិកម្ម ដី ទឹក ព្រៃឈើ និង «ធនធាន» ផ្សេងៗទៀត ដែលពាក់ព័ន្ធរបស់ពួកគេ គឺមិនមែនគ្រាន់តែជាធនធានសេដ្ឋកិច្ចប៉ុណ្ណោះទេ។ ពួកវាគឺជាប្រភពតែមួយគត់សម្រាប់ ជីវភាពរស់នៅ ពោលគឺវាមានគុណតម្លៃស្មើនឹងមូលដ្ឋានគ្រឹះនៃជីវិត វប្បធម៌ ចំណេះដឹង និងអនុស្សាវរីយ៍ដែលត្រូវបាន ចងចាំរួមគ្នា។

ប្រទេសមីយ៉ាន់ម៉ា ឡាវ និងកម្ពុជាបានក្លាយទៅជាអ្នកផ្គត់ផ្គង់ធនធានធម្មជាតិ (ដី ឈើ គ្រាប់ពូជ រុក្ខជាតិ សារធាតុរ៉ែ វារីអគ្គីសនី ត្បូងថ្ម និងឧស្ម័ន) ទំនិញកសិកម្ម (ដំឡូងមី ពោត ចេក អំពៅ សណ្តែកសៀង តែ កាហ្វេ បន្លែ គ្រាប់ស្វាយចន្ទី) និងដើមឈើឧស្សាហកម្ម (កៅស៊ូ ម៉ៃសាក់ ប្រេងខ្យល់ អាកាស្យា និងឈើពិសេស) ទៅដល់វិនិយោគិនក្នុងស្រុកនិងអន្តរជាតិដែលជាអ្នកមានទ្រព្យសម្បត្តិច្រើន និងមានខ្សែធំខ្នងក្រាស់។ ដោយហេតុថាសម្បត្តិធម្មជាតិរបស់ប្រទេសទាំងនេះត្រូវបានស្រូបទាញយកដើម្បីចិញ្ចឹមទីផ្សារ និងគណនេយ្យធនាគាររបស់វិនិយោគិន ដូចនេះប្រជាជនក្នុងស្រុកជាពិសេសប្រជាជននៅក្នុងតំបន់ជនបទ គឺពិបាកនឹងទទួលបាននូវផលប្រយោជន៍ណាស់។ ទំនិញចម្បងៗ នឹងធនធានធម្មជាតិសម្រាប់នាំចេញ និងការលក់ដីដែលល្អមានជីជាតិបំផុតទៅឲ្យក្រុមហ៊ុនកសិពាណិជ្ជកម្ម គឺកំពុងតែចាក់ឫសចាក់គល់ហើយវាមិនមែនជួយកាត់បន្ថយភាពក្រីក្រនោះទេ ខណៈដែលវាធ្វើឲ្យការមិនស្មើភាពគ្នាកាន់តែរីកធំទៅៗ។ រោងចក្រកាត់ដេរនៅក្នុងប្រទេសទាំងនេះ គឺពេញទៅដោយកម្មករវ័យក្មេងដែលភាគច្រើនគឺជាស្ត្រី ហើយដែលភាគច្រើនទៀតនោះ គឺធ្វើការច្រើនម៉ោងណាស់ ដូចនេះគ្រួសាររបស់ពួកគេអាចបន្តរក្សាបាននូវកម្មសិទ្ធិដីផ្ទះដ៏តូចរបស់ពួកគេ ពីព្រោះនេះគឺជាប្រភពនៃ សន្តិសុខសេដ្ឋកិច្ចតែមួយមុខគត់សម្រាប់ពួកគេ។ ខណៈដែលកម្មកររោងចក្រប្រហែលជាមានលុយច្រើនជាងកសិករ បន្តិចមែន ប៉ុន្តែលក្ខខណ្ឌការងារនិងសំណងគឺមិនគ្រប់គ្រាន់ខ្លាំងណាស់។ កសិករដែលបាត់បង់អ្វីៗនោះហើយបាន ក្លាយខ្លួនទៅជាកម្មករនៅចម្ការ ទទួលបានប្រាក់ឈ្នួលទាប ហើយតែងតែមិនទទួលប្រាក់ឈ្នួលម្តងពីរបីខែងណោះ។

កសិកម្មតាមកិច្ចសន្យា ត្រូវបានលើកកម្ពស់យ៉ាងខ្លាំងក្លាគគ្រឹកគគ្រេងនៅក្នុងគ្រប់ប្រទេសដែលទន្លេមេគង្គហូរកាត់ទាំងអស់ ដើម្បីធ្វើសមាហរណ៍កម្មកសិករនិងអ្នកនេសាទខ្នាតតូចចូលទៅក្នុងខ្សែសង្វាក់ផលិតកម្ម និងកែច្នៃនៅថ្នាក់តំបន់/សកល។ វាក៏ត្រូវបានប៉ាន់ស្មានទុកជាមុនដោយអង្គការអភិវឌ្ឍន៍ និងអាយអែហ្វអាយ (IFIs) មួយចំនួនដែរថាជាជម្រើសដែលអាចសម្រេចទៅបាន ដើម្បីធ្វើឲ្យវិនិយោគិនអាចទទួលបាននូវដីដែលមានសណ្ឋានទ្រង់ទ្រាយធំទូលាយ។ ខណៈដែលកិច្ចសន្យាទាំងនេះប្រហែលជាអាចផ្តល់នូវប្រាក់ចំណូលខ្លះដល់កសិករនៅក្នុងរយៈពេលខ្លីក៏ពិតមែន ប៉ុន្តែលក្ខខណ្ឌនៃកិច្ចសន្យាវិញ គឺគ្រប់គ្រងដោយក្រុមហ៊ុនសាជីវកម្មកសិពាណិជ្ជកម្ម និងពួកឈ្មួញកណ្តាល ហើយតែងតែមិនបម្រើឲ្យផលប្រយោជន៍របស់អ្នកធ្វើកសិកម្មខ្នាតតូចនោះទេ។ នៅកម្ពុជា និងឡាវ កសិករខ្នាតតូចកំពុងតែប្រឈមនឹងវិបត្តិហិរញ្ញវត្ថុធ្ងន់ធ្ងរ ពីព្រោះតែបំណុលដែលពាក់ព័ន្ធនឹងកសិកម្មតាមកិច្ចសន្យា។ បទពិសោធន៍របស់ប្រទេសថៃជាង៣០ឆ្នាំកន្លងមកនេះ ដែលបានទុកចោលកសិករខ្នាតតូចឲ្យមានភាពងាយរងគ្រោះពីទីផ្សារដោយគ្មានការការពារនោះ គឺជារឿងរ៉ាវសម្រាប់ជាការព្រមានមួយ។ នៅកម្ពុជា ឡាវ និងថៃ បំណុលដោយសារតែធ្វើកសិកម្ម និងការធ្វើចំណាកស្រុកដោយសារតែគ្មានជម្រើសគឺមានអត្រាខ្ពស់ ហើយមានគ្រួសារកសិករជាច្រើនបានបាត់បង់ដីធ្លីរបស់ពួកគេ ពីព្រោះតែមានបំណុលច្រើន ហើយពួកគេមិនអាចបង់ទាន់។ ចំពោះអ្នកដែលធ្លាប់រស់នៅអាស្រ័យផលជាមួយនឹងដី ព្រៃ និងទន្លេរបស់ពួកគេនោះ ឥឡូវនេះប្រែជាត្រូវព្យាយាមរស់ ដោយធ្វើការជាគូលីកម្មករនៅក្នុងឧស្សាហកម្មសំណង់ សេវាកម្ម បដិសណ្ឋារកិច្ច និងកំសាន្តទៅវិញ ដែលលក្ខខណ្ឌការងារអាចមានគ្រោះថ្នាក់ គ្មានសុវត្ថិភាព មានប្រាក់ឈ្នួលទាប និងមានការកេងប្រវ័ញ្ចខ្លាំង។

ចំពោះឧស្សាហកម្មទេសចរណ៍វិញ មានទំនិញ និងសេវាកម្មជាច្រើនប្រភេទ រាប់តាំងពីនីតិវិធីនៃការធ្វើអន្តោប្រវេសន៍ មធ្យោបាយដឹកជញ្ជូនតាមផ្លូវអាកាស ផ្លូវដែក ផ្លូវគោក និងផ្លូវទឹក ការធ្វើបដិសណ្ឋារកិច្ច និងការរៀបចំកន្លែងស្នាក់នៅ ដើម្បីផ្តល់នូវអាហារ ភេសជ្ជៈ កេរដំណែលប្រវត្តិសាស្ត្រនិងវត្ថុបុរាណការថែរក្សាបរិស្ថាន និងសន្តិសុខ ដែលបង្កើតនូវការងារ ប្រាក់ចំណូល និងប្រាក់ចំណូលរបស់រដ្ឋ (តាមរយៈពន្ធផ្សេងៗ)។ ទន្ទឹមគ្នានេះដែរ វិស័យទេសចរណ៍ត្រូវបានប្រើប្រាស់ជាវិធីស្រូបយក និងកេងប្រវ័ញ្ចលើធនធានមានតម្លៃ ទំនិញ និងសេវាកម្មនានា ដូចជាដី ទឹក អគ្គីសនី និងចំណីអាហារដែលទាំងអស់នេះអាចនាំឲ្យធនធានមានការថយចុះ ពីព្រោះតែការប្រើប្រាស់កើនឡើងច្រើនហួសកម្រិត (ឧទាហរណ៍ ទឹក ត្រី និងសត្វរស់នៅក្នុងទឹកផ្សេងៗទៀត) និងការបំពុលបរិស្ថាន។ រីឯតម្រូវការហេដ្ឋារចនាសម្ព័ន្ធ

រួបវន្តវិញ ដូចជាព្រលានយន្តហោះ ផ្លូវថ្នល់ រមណីដ្ឋាន សណ្ឋាគារ ភោជនីយដ្ឋាន តំបន់ជាប់មាត់ទឹក សួនឧទ្យាន និងតំបន់សម្រាប់ដើរទិញឥវ៉ាន់ គឺលៃយ៉ាងណាត្រូវបង្កើតឡើងដើម្បីឲ្យវិស័យទេសចរណ៍អាចមានដំណើរការប្រព្រឹត្តទៅបាន ហើយការសាងសង់ហេដ្ឋារចនាសម្ព័ន្ធទាំងនេះទៀតសោត គឺញឹកញយណាស់តែងតែធ្វើឲ្យសហគមន៍មូលដ្ឋានចាកចេញពីទីតាំងទាំងនោះ និងបំផ្លាញប្រភពចំណីអាហារនិងទឹកនៅមូលដ្ឋាននោះ។ វិស័យទេសចរណ៍ក៏មានជាប់ពាក់ព័ន្ធនឹងការពង្រីកនូវឧស្សាហកម្មផ្លូវភេទ ការជួញដូរមនុស្ស និងអសន្តិសុខផ្លូវកាយផងដែរ ជាពិសេសចំពោះស្ត្រី កុមារ និងយុវជន។

សំណួរមួយក្នុងចំណោមសំណួរទាំងអស់ដែលមានលក្ខណៈស៊ីជម្រៅអំពីនិន្នាការវិនិយោគនៅក្នុងតំបន់ទន្លេមេគង្គនោះគឺ នៅមូលដ្ឋានតើការវិនិយោគទាំងនោះនឹងធ្វើឲ្យមានផលប៉ះពាល់យ៉ាងដូចម្តេចខ្លះដល់សេដ្ឋកិច្ច ការងារ ជីវភាពរស់រនៅ បរិស្ថាន សន្តិសុខស្បៀង និងការទទួលបាននូវសេវាសំខាន់ៗសម្រាប់ប្រជាជននៅក្នុងតំបន់ ដែលប្រជាជនភាគច្រើនធ្វើការដាំដុះដោយខ្លួនឯងគ្រាន់បានមួយគ្រប់ៗសម្រាប់តែចិញ្ចឹមជីវិតប៉ុណ្ណោះ ហើយពួកគេមានការពឹងផ្អែកអាស្រ័យផលយ៉ាងខ្លាំងក្លាទៅលើបរិស្ថានដែលនៅជុំវិញខ្លួនរបស់ពួកគេដើម្បីរស់រានមានជីវិត។ កិច្ចព្រមព្រៀងពាណិជ្ជកម្ម និងវិនិយោគ គឺកម្រនឹងបង្កើតឡើង ដោយមានការចូលរួមពីសំណាក់ប្រជាជនឬសហគមន៍នៅមូលដ្ឋានណាស់ ហើយដំណើរការចរចាលើកិច្ចព្រមព្រៀង ឬកិច្ចព្រមព្រៀងទាំងនេះ ក៏មិនត្រូវបានដាក់ឲ្យមានការត្រួតពិនិត្យ តាមបែបប្រជាធិបតេយ្យជាតិដែរ។ ផលប៉ះពាល់អវិជ្ជមាននោះគឺ ប្រជាជនទទួលបានតិចតួច ឬក៏មិនបានទទួលបាននូវយុត្តិធម៌និងសំណងទាល់តែសោះខណៈដែលការវិនិយោគ ផលប្រយោជន៍ និងអភ័យឯកសិទ្ធិរបស់វិនិយោគិនខ្នាតធំត្រូវបានការពារដោយច្បាប់ ឬដោយការរៀបចំនិងដោយទំនាក់ទំនងដែលមិនផ្លូវការនានា។ នៅក្រោមលក្ខខណ្ឌបែបនេះ ផលប្រយោជន៍របស់ប្រជាជនមូលដ្ឋានដែលទទួលបានពីការវិនិយោគខ្នាតធំគឺមានតិចតួចខ្លាំងណាស់ ហើយយឺតយ៉ាវខ្លាំងទៀតផង។

A Banana plantation in Luang Phabang, Lao PDR. Photo credit: Michael Dwyer



# ឧបសម្ព័ន្ធ

តារាងបញ្ជីវិនិយោគទុនឯកជនថ្មីៗនៅក្នុងតំបន់ទន្លេមេគង្គ ឆ្នាំ២០១៥ និង ២០១៦។

| ទីតាំង | គម្រោង | វិស័យ | ក្រុមហ៊ុន | ប្រទេសដើមរបស់ក្រុមហ៊ុន | តម្លៃ (គិតជាលានដុល្លារ) | កាលបរិច្ឆេទប្រកាស* | ចំណាំ |
|---|---|---|---|---|---|---|---|
| កម្ពុជា | សាងសង់ទំនប់វារីអគ្គិសនីនៅទន្លេតាតៃ | ថាមពល | សាជីវកម្មម៉ាស៊ីនធនធូន់ជាតិ | ចិន | ៥៤០ | ខែកញ្ញា ឆ្នាំ២០១៥ | បានបើកឲ្យដំណើរការនូវប្រតិបត្តិការពាណិជ្ជកម្មនៃរោងចក្រថាមពលអគ្គិសនីដែលមានកម្លាំង ២៤៦ មេហ្គាវ៉ាត់ (246 MW) ដែលនេះគឺជារោងចក្រទីប្រាំមួយហើយនៅក្នុងប្រទេសដែលបានសាងសង់ដោយចិនក្នុងខែធ្នូ ឆ្នាំ២០១៥ |
| ឡាវ | ពង្រីកព្រលានយន្តហោះវ៉ាតតៃយ៍ (Wattay Airport) | ដឹកជញ្ជូន | សាជីវកម្មហាហ្សាម៉ា អ៊ែនឌូ (Hazama Ando) | ជប៉ុន | ៦១ | ២០១៥ | គម្រោងពង្រីកនេះមានផែនការបញ្ចប់នៅក្នុងឆ្នាំ២០១៨។ |
| | រោងចក្រថាមពលអគ្គិសនីរ៉ែថ្មយ៉ងថ្មហុងសា (Hongsa Mine Mouth power plant) | ថាមពល | អគ្គិសនីបានពុ (Banpu) និងរដ្ឋចាបុរី (Ratchaburi) | ថៃ | ៣៧០០ | ខែធ្នូ ឆ្នាំ២០១៥ | ដោយមានសហគ្រាសរដ្ឋរបស់ឡាវ បានបញ្ចប់និងបានជ្រើសរើសឲ្យធ្វើរោងចក្រកម្តៅទីមួយនៅក្នុងខែធ្នូ ឆ្នាំ២០១៥ បន្ទាប់ពីក្រុមហ៊ុនវិស្វកម្មអគ្គិសនីជាតិចិនបញ្ចប់ការសាងសង់វា |
| | ថាមពលដែលត្រូវបញ្ជូន (ខ្សែរត់ពីកូហ៊ីងទៅណាភ្យា និងខ្សែរត់ពីណាមហ្សាមទៅហ៊្វីមួង) | ថាមពល | សាជីវកម្មវិស្វកម្មម៉ាស៊ីនចិន (CMEC) | ចិន | ៤៨៤ | ២០១៥ | កំពុងសាងសង់ចំនួនពីរខ្សែ ដែលមានតម្លៃប៉ាន់ស្មានប្រហែលជា៣៣៨លានដុល្លារ និង១៤៦លានដុល្លារ |
| | ធ្យូងថ្មសេកុង៖ គម្រោងដាក់បញ្ចូលនូវអគ្គិសនី | ថាមពល | សាជីវកម្មម៉ាស៊ីនធនធូន់ជាតិចិន (ក្រុមហ៊ុនបុត្រសម្ព័ន្ធនៃសាជីវកម្មឧស្សាហកម្មម៉ាស៊ីនជាតិចិន) (ស៊ីណូម៉ាច/ Sinomach) | ចិន | ២១០០ | ២០១៦ | រួមបញ្ចូលទាំងរ៉ែធ្យូងថ្ម និងរោងចក្រថាមពលដែលមានកម្លាំង ២X ៣៥០មេហ្គាវ៉ាត់ (2 X 350 MW) |
| | គម្រោងទំនប់វារីអគ្គិសនីណាមង៉ៀប២ (Nam Ngiep 2) | ថាមពល | សាជីវកម្មអន្តរជាតិអគ្គិសនីនិងទឹកចិន | ចិន | ... | ២០១៥ | បានបញ្ចប់ការសាងសង់ប៊ូត (BOOT) ទីពីរ (សាងសង់ គ្រប់គ្រងជាម្ចាស់កម្មសិទ្ធិ ធ្វើប្រតិបត្តិការ ផ្ទេរ) ដែលជាគម្រោងវិនិយោគលើថាមពលវារីអគ្គិសនីក្នុងឆ្នាំ២០១៥ |
| | រោងចក្រថាមពលអគ្គិសនីហុងសា (Hongsa) | ថាមពល | ក្រុមហ៊ុនវិស្វកម្មអគ្គិសនីជាតិចិន | ចិន | ១៦៨០ | ២០១៥ | បានបញ្ចប់ការសាងសង់រោងចក្រថាមពលអគ្គិសនីហុងសា (Hongsa) ដែលមានកម្លាំង ៣ x ៦២៦ មេហ្គាវ៉ាត់ (3 x 626 MW) នៅក្នុងឆ្នាំ២០១៥។ ផលចេញភាគច្រើននឹងត្រូវលក់ទៅឲ្យប្រទេសថៃ |
| | សាងសង់ទំនប់វារីអគ្គិសនីណាមម៉ាង៣ (Nam Mang 3) | ថាមពល | ក្រុមហ៊ុនវិស្វកម្មអគ្គិសនីអន្តរជាតិចិន | ចិន | .. | ២០១៥ | .. |

| ទីតាំង | គម្រោង | វិស័យ | ក្រុមហ៊ុន | ប្រទេសដើមរបស់ក្រុមហ៊ុន | តម្លៃ (គិតជាលានដុល្លារ) | កាលបរិច្ឆេទប្រកាស* | ចំណាំ |
|---|---|---|---|---|---|---|---|
| មីយ៉ាន់ម៉ា | ព្រលានយន្តហោះអន្តរជាតិហានថាវ៉ាដឌី (Hanthawaddy) | ដឹកជញ្ជូន | សាជីវកម្មជេជីស៊ី (JGC)<br>ក្រុមហ៊ុនភាគហ៊ុនយ៉ុងណាមឆាងជី<br>ព្រលានយន្តហោះអន្តរជាតិ | ជប៉ុន<br>សឹង្ហបូរី<br>សឹង្ហបូរី | ១៥០០ | ២០១៦ | បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនៃទម្រង់បែបបទការងារនៅក្នុងឆ្នាំ២០១៦។ កិច្ចព្រមព្រៀងសម្បទានត្រូវបានរំពឹងថានឹងចុះហត្ថលេខានាំពេលខាងមុខនៅក្នុងឆ្នាំ២០១៦ ហើយការសាងសង់នឹងចាប់ផ្តើមនៅក្នុងឆ្នាំ២០១៧ |
| | តំបន់សេដ្ឋកិច្ចពិសេសឃ្យោកភីយូ (Kyaukphyu) | តំបន់សេដ្ឋកិច្ចពិសេស (SEZ) | ស៊ីអាយធីអាយស៊ី (CITIC)<br>វិស្វកម្មកំពង់ផែចិននៃប្រទេសចិន<br>ក្រុមហ៊ុនអ្នកជំនួញ Merchants Holdings<br>ក្រុមហ៊ុនវិនិយោគថេដា (TEDA Investment Holdings)<br>វិស្វកម្មនិងសំណង់យុនណាន<br>ឆារ៉ន ប៉ុកភែនដ៍ (Charoen Pokphand) | ចិន<br>ចិន<br>ចិន<br>ចិន<br>ចិន<br>ថៃ | ១៨០០០ | ខែធ្នូ ឆ្នាំ២០១៥ | ទទួលបានកិច្ចព្រមព្រៀងសាងសង់ និងធ្វើប្រតិបត្តិការលើតំបន់សេដ្ឋកិច្ចពិសេស (SEZ) |
| | ផ្លូវល្បឿននៅយ៉ាំងហ្គូន (Yangon) | ដឹកជញ្ជូន | សាជីវកម្មហាលឡា (Halla) នឹងវិស្វកម្មនិងសំណង់ឡូតតេ (Lotte) | សាធារណរដ្ឋកូរ៉េ | ៦២០ | ២០១៥ | ជាមួយនឹងដៃគូក្នុងស្រុកបានស្នើសុំសាងសង់ផ្លូវល្បឿនធំមួយខ្សែ (ហៃវេយ៍/highway) ដែលមានប្រវែង ២០,៥គីឡូម៉ែត្រ តភ្ជាប់ពីយ៉ាំងហ្គោនទៅបាហ្គូ |
| | បង្គោលអង់តែនទូរគមនាគមន៍ | ទូរគមនាគមន៍ | អូស៊ីខេ (OCK) | ម៉ាឡេស៊ី | ៧៥ | ២០១៥ | ជាមួយនឹងដៃគូក្នុងស្រុកកំពុងតែសាងសង់នូវបង្គោលអង់តែន ទូរគមនាគមន៍ចំនួន៣០០០បង្គោល សម្រាប់តេឡេន័រមីយ៉ានម៉ា (Telenor Myanmar)។ នឹងវិនិយោគចំនួន ៧៥លានដុល្លារ ទៅលើការសាងសង់បង្គោលអង់តែនចំនួន៩២០បង្គោល |
| | សាងសង់ទំនប់វារីអគ្គីសនីយៃយ៍វ៉ា (Yeywa) | ថាមពល | ថាមពលចិន | ចិន | .. | ២០១៥ | .. |
| | ខ្សែបណ្តាញបញ្ជូនថាមពលដែលមានកម្លាំង ២២០គីឡូវ៉ាត់ | ថាមពល | វិស្វកម្មអគ្គីសនីហ៊ូប៊ីយ (Hubei Electric Engineering) | ចិន | .. | ២០១៥ | បានបញ្ចប់ការរៀបចំខ្សែបណ្តាញបញ្ជូនថាពលសៀគ្វីទ្វេដងដែលមានប្រវែង១៥០គីឡូម៉ែត្រ ពីស្ថានីយ៍វារីអគ្គីសនីស្វេលី (Shweli hydropower station) ទៅតំបន់វ៉ែនីគែល តាហ្គូងតូង (Tagaung Taung) |
| ថៃ | គម្រោងផ្លូវអេយស្ម័យយាន (ផ្លូវដែក) ចិននិងថៃ | ដឹកជញ្ជូន | សាជីវកម្មសំណង់ផ្លូវអេយស្ម័យយាន (ផ្លូវដែក) ចិន | ចិន | .. | ២០១៥ | បានទទួលកិច្ចសន្យាសាងសង់ផ្លូវដែកមួយខ្សែដែលមានប្រវែង៨៦៧គីឡូម៉ែត្រ តភ្ជាប់ពីខេត្តណុងខៃ (Nong Khai) ទៅទីក្រុងបាងកក និងទៅភាគខាងកើតនៃខេត្តរ៉ាក់យុង |

# និន្នាការទូទៅនៃវិនិយោគខ្នាតធំនៅក្នុងតំបន់ទន្លេមេគង្គ

| ទីតាំង | គម្រោង | វិស័យ | ក្រុមហ៊ុន | ប្រទេសដើមរបស់ក្រុមហ៊ុន | តម្លៃ (គិតជាលានដុល្លារ) | កាលបរិច្ឆេទប្រកាស* | ចំណាំ |
|---|---|---|---|---|---|---|---|
| វៀតណាម | រោងចក្រថាមពលកម្តៅណាមឌីញ១ (Nam Dinh 1) | ថាមពល | សមាគមថាមពលអេស៊ីដាប់បិលយូអេ និងតែកវ៉ាង (Taekwang) | សោឌី អារ៉ាប៊ីត | ២២០០ | ២០១៦ | សាងសង់នូវរោងចក្រថាមពលកម្តៅមួយដែលមានកម្លាំង ១២០០មេហ្គាវ៉ាត់ (1,200 MW) ដោយផ្អែកលើកិច្ចព្រមព្រៀងរយៈពេល២៥ឆ្នាំស្តីពីការស្ថាបនា ដើម្បីផ្ទេរប្រតិបត្តិការ (BOT) |
| | ថាមពលជេអែសស៊ីវិញតាន៣ (Vinh Tan 3 Energy JSC) | ថាមពល | ស៊ីអែលភី | ហុងកុង (ចិន) | .. | ២០១៥ | បានត្រៀមបរិក្ខារហិរញ្ញប្បទានពីធនាគារអភិវឌ្ឍន៍ចិន ដើម្បីទុកសាងសង់វិញតាន៣ |
| | រោងចក្រស៊ីម៉ង់សុនឡា (SonLa Cement Plant) | ផ្សេងៗ | សាជីវកម្មម៉ាស៊ីនធនធ្ងន់ជាតិចិន | ចិន | .. | ២០១៥ | បានទទួលកិច្ចសន្យាលើការតាក់តែង សាងសង់ និងដំឡើងឧបករណ៍សម្រាប់រោងចក្រស៊ីម៉ង់ |
| | រោងចក្រថាមពលកម្តៅគីញឡាប២ (Quynh Lap-2) | ថាមពល | ប៉ុស្កូ (Posco) | សាធារណរដ្ឋកូរ៉េ | .. | ខែកុម្ភៈ ឆ្នាំ២០១៦ | បានទទួលនូវកិច្ចសន្យាមួយដើម្បីសាងសង់រោងចក្រថាមពលដែលមានកម្លាំង ១២០០ មេហ្គាវ៉ាត់ (1,200 MW) ដែលជាសំណង់រោងចក្រថាមពលទីពីរនៅវៀតណាមរបស់ក្រុមហ៊ុននេះ |
| | រោងចក្រថាមពលអគ្គីសនីម៉ុងឌួង២ (Mong Duong 2) | ថាមពល | ប៉ុស្កូ (Posco)<br><br>អេអ៊ីអែស (AES)<br><br>សាជីវកម្មវិនិយោគទុនចិន | សាធារណរដ្ឋកូរ៉េ<br><br>សហរដ្ឋអាមេរិក<br><br>ចិន | ២១០០ | ខែឧសភា ឆ្នាំ២០១៥ | បានបញ្ចប់ និងបានចាប់ផ្តើមប្រតិបត្តិការពាណិជ្ជកម្មលើរោងចក្រថាមពលនៅក្នុងខែតុលា ឆ្នាំ២០១៥ ជាមួយនឹងឧស្សាហកម្មធនធ្ងន់ដូសាន (សាធារណរដ្ឋកូរ៉េ) ជាក្រុមហ៊ុនអ៊ីភីស៊ី ហើយអ្នកទទួលកិច្ចសន្យាបន្តរួមមានទាំងក្រុមហ៊ុនអគ្គីសនីយូក្ហាវ៉ា (ប្រទេសជប៉ុន) |
| | រោងចក្រថាមពលកម្តៅឌូយេនហៃយ៍២ (Duyen Hai II) | ថាមពល | តេកនីក ចាណាគួសា (Teknik Janakuasa) (ក្រុមហ៊ុនបុត្រសម្ព័ន្ធនៃអ៊ីអឹមស៊ី)(ម៉ាឡេស៊ី) | ម៉ាឡេស៊ី | ២២០០ | ២០១៥ | ទទួលបានកិច្ចព្រមព្រៀងសាងសង់រោងចក្រថាមពលកម្តៅនេះ ហើយគ្រោងនឹងបញ្ចប់នៅក្នុងឆ្នាំ ២០២០ |
| | រោងចក្រកែច្នៃឧស្ម័នកាម៉ូ (Ca Mau) | ប្រេង និងឧស្ម័ន | វិស្វកម្មនិងសំណង់ប៉ុស្កូ | សាធារណរដ្ឋកូរ៉េ | ២៤៩ | ២០១៥ | ជាមួយនឹងដៃគូក្នុងស្រុក ទទួលបានកិច្ចព្រមព្រៀងអ៊ីភីស៊ី (EPC contract) សម្រាប់រោងចក្រនេះ |
| | ប្រព័ន្ធដឹកជញ្ជូនវៃឆ្លាត (Intelligent transportation system) | ដឹកជញ្ជូន | អែសខេ (SK) ស៊ី&ស៊ី (C&C) | សាធារណរដ្ឋកូរ៉េ | .. | ២០១៥ | ទទួលបានអាជ្ញាប័ណ្ណសាងសង់ប្រព័ន្ធសម្រាប់ផ្លូវល្បឿនពីហាណូយទៅហៃហ្វុង |

ប្រភព៖ របាយការណ៍ស្តីពីការវិនិយោគនៅអាស៊ាន ឆ្នាំ២០១៦។

# NOTES


1 ហ្វ័រឃើស អន ដឺ ហ្គ្លូបិលសោធហ៍៖ ការសិក្សាស្តីពី «ស្វែងយល់ពីនិន្នាការនៃការវិនិយោគគ្មានព្រំដែន អំពីគោលនយោបាយ និងច្បាប់នៃតំបន់សេដ្ឋកិច្ចពិសេសនៅក្នុងតំបន់ទន្លេមេគង្គ ដូចជាប្រទេសកម្ពុជានិងភូមា៖ របាយការណ៍ផ្ទៃក្នុងឆ្នាំ២០១៦ស្តីពីសិទ្ធិរបស់វិនិយោគិន ប្រឆាំងនឹងសិទ្ធិរបស់ប្រជាជន។

2 https://www.adb.org/countries/gms/overviewបានចូលមើលនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៦

3 http://www.mrcmekong.org/mekong-basin/physiographyបានចូលមើលនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦

4 http://www.mrcmekong.org/mekong-basin/natural-resourcesបានចូលមើលនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦

5 ស្ថិតិរបស់មហាអនុតំបន់ទន្លេមេគង្គស្តីពីការរីកចម្រើន ហេដ្ឋារចនាសម្ព័ន្ធ និងពាណិជ្ជកម្ម (បោះពុម្ពលើទីពីរ)៖ វេទិកាច្រករបៀងសេដ្ឋកិច្ចទាំងប្រាំបី ៣-៤ ឆ្នាំ២០១៦ ទីក្រុងភ្នំពេញ ប្រទេសកម្ពុជា។https://www.adb.org/sites/default/files/institutional-document/189958/gms-statistics-2nd-ed.pdfបានចូលមើលនៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦។

6 ទិន្នន័យពុំបានដាក់បញ្ចូលខេត្តយុនណានរបស់ប្រទេសចិនទេ។ ឯកសាររបស់ធនាគារពិភពលោកអំពីពលករ៖ សរុបតាមប្រទេសសម្រាប់ឆ្នាំ២០១៤។http://data.worldbank.org/indicator/SL.TLF.TOTL.IN

7 របាយការណ៍ឆ្នាំ២០១៦ស្តីពីការវិនិយោគទុននៅអាស៊ាន៖ ការវិនិយោគទុនផ្ទាល់ពីបរទេស និងអ៊ឹមអ៊ែសអ៊ឹមអ៊ី (MSME)។ តំណភ្ជាប់៖ http://asean.org/storage/2016/09/ASEAN-Investment-Report-2016.pdf

8 សេចក្តីសង្ខេបបន្ថែមពីការវិនិយោគទុនផ្ទាល់ពីបរទេស និងការទទួលបានដីធ្លី។ ដោយ ណាតាលី ស្គូរ៉ាហ៍ (Natalia Scurrah) និងហ្វីលីប ហ៊ីសច៍ (Philip Hirsch)។ វេទិកាស្រាវជ្រាវពីទឹកដីតំបន់ទន្លេមេគង្គ។ អស៊ីអ៊ែសឌី (RCSD)។ ខែធ្នូ ឆ្នាំ២០១៥។

9 ក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច៖ ទិដ្ឋភាពទូទៅនៃគោលនយោបាយ និន្នាការ និងគម្រោងវិនិយោគឯកជនក្នុងប្រទេសកម្ពុជា។ ដោយ ម៉ាខ គ្រីមស្ដីច (Mark Grimsditch)។ ហ្វ័រឃើស អន ដឺ គ្លូបិលសោធហ៍។ ខែឧសភា ឆ្នាំ២០១៦។http://focusweb.org/content/engine-economic-growth-overview-private-investment-policies-trends-and-projects-cambodia

10 ធនាគារអភិវឌ្ឍន៍អាស៊ី។ តារាងសូចនាករសំខាន់ៗតាមប្រទេសសម្រាប់អាស៊ីនិងប៉ាស៊ីហ្វិចឆ្នាំ២០១៦៖ កម្ពុជា https://www.adb.org/sites/default/files/publication/204091/cam.pdf

11 ធនាគារអភិវឌ្ឍន៍អាស៊ី។ ទស្សនៈវិស័យលើការអភិវឌ្ឍនៅអាស៊ី ឆ្នាំ២០១៦៖ សក្តានុពលនៃភាពរីកចម្រើនរបស់អាស៊ី។https://www.adb.org/sites/default/files/publication/182221/ado2016.pdf

12 Council of Development of Cambodia. http://www.cambodiainvestment.gov.kh/investment-scheme/investment-incentives.html; បានចូលមើលនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦។

13 លីកាដូ៖ អត្ថបទ៖ ការពិនិត្យមើលឡើងវិញលើហេតុការណ៍នានាក្នុងឆ្នាំ២០១៣៖ វិបត្តិដីធ្លីនៅក្នុងប្រទេស។ http://www.licadho-cambodia.org/articles/20140321/142/index.html

14 បេសកកម្មស្វែងរកការពិត៖ របាយការណ៍ពីកម្ពុជាស្តីពីសប្តាហ៍មួយដែលបានធ្វើឲ្យកម្ពុជារង្គោះរង្គើ៖ សេចក្តីសង្ឃឹម កំហឹង និងការអស់សង្ឃឹមរបស់កម្មករកម្ពុជាបន្ទាប់ពីកូដកម្មទូទៅនិងការបង្ក្រាបយ៉ាងហិង្សា (ខែធ្នូ ឆ្នាំ២០១៣ ដល់ ខែមករា ឆ្នាំ២០១៤)។http://www.uniontounion.org/pdf/FFM-Cambodia-Report.pdf

15 ភ្នំពេញប៉ុស្តិ៍៖ សកម្មជនផ្នែកអភិរក្សត្រូវបានចាប់ខ្លួននៅខេត្តកោះកុង។ ថ្ងៃអង្គារ ទី១៨ ខែសីហា ឆ្នាំ២០១៥។http://www.phnompenhpost.com/national/conservation-activists-arrested-koh-kong

16 ទិសដៅនៃការវិនិយោគ និងរដ្ឋបាលរបស់ក្រុមហ៊ុននៃសាធារណរដ្ឋនៃសហភាពមីយ៉ាន់ម៉ាhttp://www.dica.gov.mm/en/topic/foreign-investment-sectorបានចូលមើលនៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦។

17 http://www.dica.gov.mm/en/special-economic-zones;បានចូលមើលនៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦។

18 បញ្ជីរាយនាមវិនិយោគទុនបរទេសដែលទទួលបានការអនុម័ត គិតត្រឹម (៣១/១០/២០១៦)http://www.dica.gov.mm/sites/dica.gov.mm/files/document-files/by_country1.pdfបានចូលមើលនៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦។

19 http://www.investlaos.gov.la/index.php/resources/statisticsបានចូលមើលនៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៦

20 Ibid

21 http://www.investlaos.gov.la; accessed on December 22, 2016

22 http://www.vietrade.gov.vn/en/index.php?option=com_content&view=article&id=795&Itemid=201; accessed on December 28th, 2016.

23 Ibid

24 តំបន់ដីសណ្តទន្លេមេគង្គ ការលេចចេញនូវកន្លែងគោលដៅសម្រាប់ធ្វើវិនិយោគទុននៅក្នុងប្រទេសវៀតណាម ភាពរីកចម្រើនប្រកបដោយចីរភាព ការធ្វើឲ្យហេដ្ឋារចនាសម្ព័ន្ធមានភាពប្រសើរឡើង និងបរិយាកាសវិនិយោគដ៏ល្អអស្ចារ្យ។ អង្គការកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ)ជីអ៊ឹមប៊ីអេច (GmbH)។ ខែវិច្ឆិកា ឆ្នាំ២០១៥។

25 បទបង្ហាញរបស់ហ្សាវីយេ ហ្វូនណឺរីស មកពីធនាគារពិភពលោកស្តីពី ប្រទេសថៃ៖ បរិយាកាសនៃការវិនិយោគរបស់វិនិយោគទុនផ្ទាល់ពីបរទេស គោលនយោបាយវិនិយោគ។ ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៦។http://www.fpo.go.th/FPO/modules/Content/getfile.php?contentfileID=10261

26 អាយប៊ីអាយឌី (Ibid)

27 មគ្គុទេសក៍សម្រាប់ក្រុមប្រឹក្សាវិនិយោគ ឆ្នាំ២០១៦។http://www.boi.go.th/upload/content/BOI-A_Guide_2016-EN-20160930_84388.pdf

28 http://www.boi.go.th/index.php?page=policies_for_investment_promotionបានចូលមើលនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៦។

29 http://www.adb.org/countries/gms/overviewបានចូលមើលនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៦

30 ការពិនិត្យឡើងវិញលើការរៀបចំច្រករបៀងសេដ្ឋកិច្ចនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ។ អគ្គលេខាធិការដ្ឋានមហាអនុតំបន់ទន្លេមេគង្គ នាយកដ្ឋានប្រចាំតំបន់អាស៊ីអាគ្នេយ៍ ធនាគារអភិវឌ្ឍន៍អាស៊ី ខែវិច្ឆិកា ឆ្នាំ២០១៦

31 ផែនការអនុវត្តក្របខណ្ឌវិនិយោគនៅមហាអនុតំបន់ទន្លេមេគង្គ (២០១៤-២០១៨)។ ធនាគារអភិវឌ្ឍន៍អាស៊ី ឆ្នាំ២០១៤-២០១៥។ អាចទាញយកបាននៅ៖ http://www.adb.org/countries/gms/strategy

32 អាយប៊ីអាយឌី (Ibid)។ ទំព័រទី១៣

33 http://investasean.asean.org/index.php/page/view/asean-economic-community/view/670/newsid/755/about-aec.html បានចូលមើលនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៦

34 http://investasean.asean.org/files/upload/Sec.%203_Envi_1_AEC_Annex%203_Outcomes%20and%20Benefits%20(Aug%20version).pdfបានចូលមើលនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៦

35 http://www.acmecsorg.com/index.php?id=9បានចូលមើលនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៦

36 http://asean.org/storage/2016/10/Ha-Noi-Declaration_7th-ACMECS-Summit_FINAL.pdfបានចូលមើលនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៦

37 http://www.fmprc.gov.cn/mfa_eng/zxxx_662805/t1350039.shtmlបានចូលមើលនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦

38 http://ec.europa.eu/trade/policy/countries-and-regions/regions/asean/បានចូលមើលនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦

39 កិច្ចព្រមព្រៀងវិនិយោគទុនអន្តរជាតិ(IIAs)រួមបញ្ចូលទាំងសន្ធិសញ្ញាវិនិយោគទ្វេភាគី (BITs) និងសន្ធិសញ្ញាស្តីពីការផ្តល់វិនិយោគទុន (TIPs)

40 http://investmentpolicyhub.unctad.org/IIA/IiasByCountry#iiaInnerMenuបានចូលមើលនៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៦

41 ការសិក្សាស្រាវជ្រាវថ្មីរបស់ធនាគារអភិវឌ្ឍន៍អាស៊ីបានបង្ហាញពីការរៀបចំតាក់តែងតំបន់សេដ្ឋកិច្ចពិសេសត្រូវបានកំណត់ថាជាជោគជ័យ ដែលបានចេញផ្សាយនៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៥។ https://www.adb.org/news/new-adb-research-shows-design-special-economic-zones-determines-successបានចូលមើលនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦។

42 ប្រភព៖ ចន វ៉លស្ហ៍ (John Walsh)៖ ខែឧសភា ឆ្នាំ២០១៥ (ឯកសារពិសន្និសីទ លេខ ១៩)៖ តំបន់សេដ្ឋកិច្ចពិសេសរបស់មហាអនុតំបន់ទន្លេមេគង្គ៖ ភាពជាម្ចាស់កម្មសិទ្ធិដីធ្លី និងការផ្លាស់ប្តូររបស់សង្គម។ ធនាគារអភិវឌ្ឍន៍អាស៊ីhttps://www.adb.org/sites/default/files/institutional-document/214316/role-sez-gms.pdfនាយកដ្ឋានលើកកម្ពស់ការវិនិយោគនៃប្រទេសឡាវ (បញ្ជីឈ្មោះតំបន់សេដ្ឋកិច្ចពិសេសដែលបានធ្វើបច្ចុប្បន្នភាពចុងក្រោយបំផុត៖ ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៦)http://www.investlaos.gov.la/index.php/where-to-invest/special-economic-zone?limitstart=0បានចូលមើលនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦។

43 ការវិនិយោគអន្តរប្រទេសនិងទំនួលខុសត្រូវលើយុត្តិធម៌សង្គមនិងបរិស្ថាន៖ មេរៀនពីគោលនយោបាយនិងការអនុវត្តការអភិវឌ្ឍឧស្សាហកម្មរបស់ប្រទេសជប៉ុននិងថៃ។ ហ្សាវ អ៊ូង សមាគមនាយកដ្ឋានដាវេយ៍ (DDA) ឆ្នាំ២០១៦

Farmers harvesting in Otdar Meanchey province, Cambodia, 2016. Photo credit: Ridan Sun



4th Floor Wisit Prachuabmoh Building
Chulalongkorn University, Phayathai Road
Bangkok 10330, THAILAND
Tel: +66 2 218 7363
Fax: +66 2 255 9976
www.focusweb.org